គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា

NEUTRAL AND IMPARTIAL COMMITTEE FOR FREE AND FAIR ELECTION IN CAMBODIA

និកហ្វិច/ NICFEC

## ឯកសារបណ្តុះបណ្តាល

# វិមជ្ឈការ

# អភិបាលកិច្ចល្អ

រៀងដោយ និកហ្វិច
NICFEC

ឧបត្ថម្ភដោយ គណៈកម្មការសហគមន៍អឺរ៉ុប
EUROPEAN COMMISSION

354.968
DEC

# មាតិកា

ទំព័រ

I. **កម្មវិធីសិក្ខាសាលា**

II. **គោលបំណងនៃ សិក្ខាសាលា** ១

III. **អត្ថន័យនៃវិមជ្ឈការ** ៣

១. អំណាច តួនាទី និងមុខងារ របស់ក្រុមប្រឹក្សា ឃុំ ,សង្កាត់ ៤

២. ចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា ឃុំ /សង្កាត់ ៦

៣. តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់អ្នកចូលរួមនានា នៅក្នុងការអភិវឌ្ឍន៍ឃុំ /សង្កាត់ ៩

៤. ការកំណត់ទិសដៅសំរាប់វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាល ឃុំ /សង្កាត់ ១២

៥. បណ្តាញគាំទ្រដល់ឃុំ /សង្កាត់ ១៤

៦. ប្រតិភូកម្មភារកិច្ច និងការទទួលខុសត្រូវ ១៦

IV. **អភិបាលកិច្ចល្អ** ១៨

១. ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ ១៨

២. ការចូលរួម ២០

៣. នីតិរដ្ឋ ២២

៤. តម្លាភាព ២៤

៥. ការព្រមព្រៀងឯកភាពគ្នា ២៦

៦. សីលធម៌នៃអភិបាលកិច្ចល្អ ២៧

៧. ប្រសិទ្ធិភាព ២៨

៨. គណនេយ្យភាព ៣១

៩. ការឆ្លើយតប ៣៣

**V. ការបញ្ជ្រាបយេនឌ័រទៅក្នុងស្រទាប់នៃសង្គម** ៣៤

១. និយមន័យអំពីភេទ និង យេនឌ័រ ៣៧

២. តួនាទីយេនឌ័រ និងតំរូវការយេនឌ័រ ៣៨

៣. ការចូលរួមនិងការទទួលបានការប្រើប្រាស់ និងគ្រប់គ្រងលើធនធាន ៤២

៤. ការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីផ្សេងៗ ៤២

៥. យុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រ ៤៤

**VI. ប្រសិទ្ធិភាពនៃការធ្វើការងារជាក្រុម** ៤៨

១. ប្រសិទ្ធិភាពនៃការធ្វើការងារជាក្រុម ៤៨

២. ការមិនប្រកាន់និន្នាការនយោបាយ ៥១

៣. ការគោរពតួនាទី ភារកិច្ច និងកិច្ចសហការគ្នា ៥២

**VII. ការអភិវឌ្ឍន៍ដែលមានការចូលរួមពីប្រជាពលរដ្ឋ** ៥៣

១. ផលប្រយោជន៍នៃការចូលរួម ៥៤

២. ការជំរុញការចូលរួមរបស់សាធារណៈជន ៥៥

# គោលបំណងនៃសិក្ខាសាលា

រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តនយោបាយវិមជ្ឈការ ក្នុងគោលបំណងលើកកំពស់លទ្ធិប្រជាធិបតេយ្យអោយកាន់តែធំធាត់ រីកចំរើនតាំងពីថ្នាក់លើដល់ថ្នាក់មូលដ្ឋាន ដើម្បីរួមចំនែកអភិវឌ្ឍន៍ប្រទេសជាតិ ។ តាមរយៈនេះ រដ្ឋាភិបាលបានដាក់ជាគោលនយោបាយចតុកោណដែលក្នុងនោះ បានផ្តោតសំខាន់លើការអភិវឌ្ឍន៍ពីថ្នាក់មូលដ្ឋានឡើងទៅ។ កត្តាទាំងនេះទាមទារអោយមានការអនុវត្តតាមប្រពន្ធ័វិមជ្ឈការ និង អភិបាលកិច្ចល្អ តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិ ឃុំ និងតំរូវអោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ ពិសេសអាជ្ញាធរមូលដ្ឋានដែលជាអ្នកដឹកនាំសកម្មភាព ។
ហេតុដូច្នេះហើយអ្នក ទាំងអស់នោះត្រូវតែស្គាល់ អំពីតួនាទី ភារកិច្ច សារប្រយោជន៍ វិធីសាស្ត្រ និងចូលរួមយ៉ាងសកម្មដើម្បីអនុវត្តគោលការខាងលើរៀងខ្លួន។

ទោះជាយ៉ាងនេះក្តី បើយើងខ្វះធនធានមនុស្ស ពិសេសខ្វះថ្នាក់ដឹកនាំល្អ ក៏ការអនុវត្តគ្មានប្រសិទ្ធិភាពដែរ ធនធានមនុស្សជាទ្រព្យយ៉ាងសំខាន់បំផុតសំរាប់ស្តារ និងអភិវឌ្ឍន៍ប្រទេស ។ ស្ត្រីជាធនធានយ៉ាងសំខាន់ដែលកំណាប់នេះយើងបានបំភ្លេចចោល ហើយយើងតែងតែគិតថាស្ត្រីអសមត្ថភាព មិនអាចធ្វើការធំបាន ក្នុងនេះជាង៥០%នៃប្រជាជនកម្ពុជា ជាស្ត្រីដែលជាកំលាំងដ៏មុតស្រួចមិនអាចខ្វះបាន។

ដើម្បីឆ្លើយតបនឹងកង្វះខាតផ្នែកធនធានខាងលើនេះ រាជរដ្ឋាភិបាលក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលបានខិតខំជំរុញអោយមានសមភាពផ្នែកយេនឌ័រ ដោយបញ្ជ្រាបពីតួនាទីរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ ។

ដោយមើលឃើញពីភាពចាំបាច់ទាំងនេះទើបគណៈកម្មាធិការ និកហ្វិច ដោយមានការឧបត្ថម្ភរបស់គណកម្មការសហគមន៍អឺរ៉ុបបានរៀបចំបើកសិក្ខាសាលាពង្រឹងចំណេះដឹង ស្តីអំពី វិមជ្ឈការ អភិបាលកិច្ចល្អ ការបញ្ជ្រាបយេនឌ័រទៅក្នុងស្រទាប់សង្គម ប្រសិទ្ធិភាពនៃការធ្វើការងារជាក្រុម និង ការអភិវឌ្ឍន៍ ដែលមានការចូលរួមពីប្រជាពលរដ្ឋ ដល់ក្រុមប្រឹក្សាឃុំ .សង្កាត់ និងស្ថាប័នពាក់ពន្ធ័ផ្សេងៗ ។

បន្ទាប់ពីបញ្ចប់វគ្គសិក្ខាសាលា យើងរំពឹងទុកថា សិក្ខាកាមនឹងទទួលបានចំណេះដឹង និងជំនាញមូលដ្ឋានអំពី :

¤ ស្គាល់អំពីអត្ថន័យនៃវិមជ្ឈការ

¤ ស្គាល់អំពីអត្ថន័យនៃវិមជ្ឈការ

¤ ស្គាល់អំពីតំលៃ ឬសារប្រយោជន៍វិមជ្ឈការ

¤ ស្គាល់អំពីតួនាទី និងភារកិច្ចរបស់ប្រជាពលរដ្ឋ តួនាទីនិងភារកិច្ចរបស់ថ្នាក់ដឹកនាំសំខាន់ៗ និងតួនាទីរបស់

¤ អ្នកចូលរួមផ្សេងៗទៀត ក្នុងប្រពន្ធ័វិមជ្ឈការ

¤ យល់បានអំពីអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ.សង្កាត់ និងអ្នកពាក់ពន្ធ័សំខាន់ៗមួយចំនួនទៀតក្នុងការអភិវឌ្ឍន៏

¤ ជំរុញទឹកចិត្តសិក្ខាកាមអោយមានភាពក្លាហានក្នុងការទាមទារអោយមានការគ្រប់គ្រងតាមប្រពន្ធ័វិមជ្ឈការ

¤ មានសមត្ថភាពក្នុងការអនុវត្តតាមប្រពន្ធ័វិមជ្ឈការ

¤ ចូលរួមអនុវត្តក្នុងប្រពន្ធ័វិមជ្ឈការ

¤ យល់អំពីទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ

¤ យល់អំពីតំលៃរឺសារសំខាន់នៃអភិបាលកិច្ចល្អ

¤ យល់អំពីតួនាទីរបស់អ្នកចូលរួមក្នុងអភិបាលកិច្ចល្អ

¤ ចូលរួមអនុវត្តតាមតួនាទីរៀងខ្លួន

¤ យល់អំពីអត្ថន័យយេនឌ័រ

¤ យល់អំពីតួនាទី និងតំរូវការយេនឌ័រ

¤ ធ្វើការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីផ្សេងៗ

¤ យល់អំពីប្រសិទ្ធិភាពនៃការធ្វើការងារជាក្រុម និងរួមគ្នាធ្វើការងារ ដោយឈរលើជំហរសមភាពយេនឌ័រ និងមិនប្រកាន់និន្នាការនយោបាយ

¤ យល់អំពីភាពចាំបាច់នៃតួនាទីរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៏

¤ ផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន

# អត្ថន័យនៃវិមជ្ឈការ

វិមជ្ឈការមានន័យថា សិទ្ធិការទទួលខុសត្រូវ និងធនធានមួយចំនួនត្រូវបានផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលបានបោះឆ្នោត ជ្រើសរើសឡើងតាមលក្ខណៈលទ្ធិប្រជាធិបតេយ្យ ។

តើមានទិដ្ឋភាពសំខាន់ៗអ្វីខ្លះនៅក្នុងវិមជ្ឈការ ?

- ប្រជាពលរដ្ឋមានសិទ្ធិ បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ .សង្កាត់
- ប្រជាពលរដ្ឋត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវ ដើម្បីដើរតួនាទីយ៉ាងសកម្មក្នុងជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំ /សង្កាត់ និងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន ។
- នៅទូទាំងប្រទេសកម្ពុជាមានឃុំ/សង្កាត់ទាំងអស់ចំនួន**១.៦២១** ដោយមានក្រុមប្រឹក្សាដែលបានបោះឆ្នោតជ្រើសរើសឡើង ។ ក្រុមប្រឹក្សាទាំងនេះតំណាងអោយប្រជាពលរដ្ឋនៅក្នុងឃុំ /សង្កាត់របស់ខ្លួន ។
- ក្រុមប្រឹក្សាឃុំ/សង្កាត់មានអាណត្តិ ៥ ឆ្នាំ ។ បន្ទាប់មកនឹងមានការបោះឆ្នោតម្តងទៀត ។
- ក្រុមប្រឹក្សាឃុំ /សង្កាត់ ត្រូវផ្តល់ការទទួលខុស និងភារកិច្ចជាច្រើន ។ ការទទួលខុសត្រូវ និងភារកិច្ចទាំងនេះ ខុសប្លែកទាំងស្រុងពីការទទួលខុសត្រូវ និងភារកិច្ចរបស់ឃុំ .សង្កាត់កាលពីមុន ។ ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ គឺគាំទ្រការអភិវឌ្ឍន៍ឃុំ.សង្កាត់ និង សុខាមាលភាពរបស់ប្រជាពលរដ្ឋ។
- ក្នុងការបំពេញភារកិច្ចរបស់ខ្លួន សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់មានការទទួលខុសត្រូវ និងមានគណនេយ្យភាពទាំងស្រុងចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។
- ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវធានាថា សហគមន៍នៅមូលដ្ឋានចូលរួមយ៉ាងត្រឹមត្រូវនៅក្នុងដំណើរការធ្វើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ។ ការចូលរួមនេះជាការសំខាន់ណាស់ ពីព្រោះសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់នឹងធ្វើសេចក្តីសំរេចនានាដែលមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជា សមាជិកក្រុមប្រឹក្សាធ្វើសេចក្តីសំរេចលើការចំនាយធនធានដែល ក្រុមប្រឹក្សានេះមាន ។

- ដើម្បីអនុវត្តការកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាឃុំ /សង្កាត់ត្រូវមានធនធានហិរញ្ញវត្ថុ និងបុគ្គលិក របស់ខ្លួនផ្ទាល់ ដើម្បីគាំទ្រក្រុមប្រឹក្សារបស់ខ្លួន ។ ក្រុមប្រឹក្សាឃុំ.សង្កាត់មានស្មៀនមួយរូបដែល ត្រូវតែងតាំងដោយក្រសួងមហាផ្ទៃ ។

## ១. អំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ,សង្កាត់

**ច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាល ឃុំ/សង្កាត់ មាត្រា ៤១ ចែងថា :**
រដ្ឋបាលឃុំ /សង្កាត់ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធានដែលមាន សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ / សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិស្របតាមគោលនយោបាយរបស់រដ្ឋ ។

ផ្អែកតាមបទបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវបានផ្តល់ជូននូវអំណាច តួនាទី និងមុខងារដូចខាងក្រោម :

### + អំណាច :

ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវបានផ្តល់ជូននូវអំណាចឱ្យគ្រប់គ្រង និងចាត់ចែងកិច្ចការក្នុងឃុំ/សង្កាត់ របស់ខ្លួន ។ ក្រុមប្រឹក្សានេះត្រូវបំរើផលប្រយោជន៍រួមរបស់ ឃុំ /សង្កាត់ ។

ក្រុមប្រឹក្សាឃុំ/សង្កាត់ មាន**អំណាចបញ្ញត្តិ** មានន័យថា ក្រុមប្រឹក្សាឃុំ/សង្កាត់អាចសំរេចចេញដីកានៅក្នុងក្របខ័ណ្ឌតួនាទី និងការទទួលខុសត្រូវដែលរដ្ឋបានប្រគល់អោយ ។ ដីកាមានអនុភាពអនុវត្តតែនៅក្នុងដែនដីរបស់ឃុំ.សង្កាត់ប៉ុណ្ណោះ ។ ដីកាមិនត្រូវផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រិត្យ សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ។ ប្រសិនបើដីកាណាមួយដែលផ្ទុយនឹងលិខិត បទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹងត្រូវចាត់ទុកជាមោឃៈ ។ ក្រុមប្រឹក្សា ឃុំសង្កាត់មានអំណាចប្រតិបត្តិ មានន័យថា ក្រុមប្រឹក្សាមានសិទ្ធិអនុវត្តសេចក្តីសំរេចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌ តួនាទី និងការទទួលខុសត្រូវដែលច្បាប់បានប្រគល់ឱ្យ ។

## ✦ តួនាទី និងមុខងារ :

តួនាទីនិងការទទួលខុសត្រូវសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ គឺត្រូវជំរុញយ៉ាងសកម្ម នូវការអភិវឌ្ឍន៍ឃុំ /សង្កាត់ និងសុខាមាលភាពរបស់ប្រជាពលរដ្ឋ ។ ក្រុមប្រឹក្សានេះ ត្រូវប្រើប្រាស់អោយបានត្រឹមត្រូវនូវធនធានដែលមានទាំងអស់ ក្រុមប្រឹក្សាត្រូវប្រើប្រាស់ ធនធានទាំងនោះដើម្បីបំរើអោយសេចក្តី ត្រូវការ របស់ឃុំ /សង្កាត់ និងរបស់ប្រជាពលរដ្ឋ ។

ក្រុមប្រឹក្សាឃុំ /សង្កាត់ មានភារកិច្ចបំរើកិច្ចការមូលដ្ឋាន ។ ភារកិច្ចមួយចំនួនដូចជា :

- គ្រប់គ្រងសេវាសាធារណៈដែលចាំបាច់ និងធានាថាសេវាទាំងនេះដំណើរការល្អដូចជាការប្រមូលកាកសំណល់ និងសំរាមនៅក្នុងនៅក្នុងមូលដ្ឋាន.....។ល។
- ការពារបរិស្ថាន និងធនធានធម្មជាតិដូចជា ក្រុមប្រឹក្សាត្រូវជួយប្រជាពលរដ្ឋក្នុងការថែរក្សាទន្លេ និងបរិស្ថាននៅក្នុងភូមិស្ថានអោយបានល្អ និងមិនអោយទទួលរងការបំផ្លាញ ។
- ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមដូចជា ក្រុមប្រឹក្សាឃុំ,សង្កាត់អាចសម្របសម្រួលកិច្ចសហប្រតិបត្តិការល្អជាមួយអង្គការសង្គមស៊ីវិល ក្រុមប្រឹក្សាឃុំ /សង្កាត់អាចលើកទឹកចិត្តអោយពាណិជ្ជករ មករស់នៅ និងធ្វើអាជីវកម្មនៅក្នុងតំបន់របស់ខ្លួន ។
- លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចជាក្រុមប្រឹក្សាឃុំ /សង្កាត់ ត្រូវកសាងផែនការដើម្បីអនុវត្តអ្វីដែលប្រជាពលរដ្ឋមើលឃើញថា ជាសេចក្តីត្រូវការជាអទិភាពដូចជា បញ្ហាទឹកស្អាត ការអប់រំ ឬសុខភាព... ។ល។
- លើកកំពស់ការសណ្តោសប្រណី និងការយោគយល់ក្នុងចំណោមប្រជាពលរដ្ឋដូចជា ឃុំ /សង្កាត់ ត្រូវជួយដោះស្រាយជម្លោះដែលអាចកើតមានក្នុងចំណោមប្រជាពលរដ្ឋ ។
- រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ ភារកិច្ចនេះត្រូវធ្វើឡើងទៅតាមរូបភាពអហិង្សា ។ ក្រុមប្រឹក្សាឃុំ,សង្កាត់ មិនអាចបង្កើតកំម្លាំងនគរបាល ឬកងទ័ពទេ។

ក្រៅពីនេះ ក្រុមប្រឹក្សាឃុំ,សង្កាត់មានភារកិច្ចដែលគាត់បំពេញក្នុងនាមរដ្ឋបាលថ្នាក់កណ្តាល ។ ភារកិច្ចបែបនេះហៅថា មុខងារជាភ្នាក់ងារ ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងឃុំ ,សង្កាត់ ។ ក្នុងករណី ដែលក្រុមប្រឹក្សាឃុំ,សង្កាត់បំពេញការងារក្នុងនាមរដ្ឋ ក្រុមប្រឹក្សាឃុំ/សង្កាត់ក៏ទទួលបានការគាំទ្រពីរដ្ឋផងដែរ ។ ឧទាហរណ៍ : ក្រុមប្រឹក្សាឃុំ ,សង្កាត់ទទួលបានសម្ភារៈ ឬហិរញ្ញវត្ថុ និងការបណ្តុះបណ្តាល

ដើម្បី អនុវត្តភារកិច្ចទាំងនេះ ។

### + ព្រំដែននៃអំណាច

ក្រុមប្រឹក្សាឃុំ/សង្កាត់ អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារ ដែលច្បាប់បានប្រគល់អោយតែប៉ុណ្ណោះ ។ មានន័យថា ក្រុមប្រឹក្សាមិនអាចធ្វើសកម្មភាពផ្ទុយនឹងគោលការណ៍ និងបទបញ្ជាដែលបានកំណត់ឡើង ដូចជា រដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិ អនុក្រឹត្យ ឬប្រកាសនានាឡើយ ។ ចំពោះកិច្ចការមួយចំនួនដែលជាផលប្រយោជន៍របស់ជាតិ ក្រុមប្រឹក្សាឃុំ /សង្កាត់ គ្មានអំណាចឡើយ ។ កិច្ចការទាំងនេះ ហួសពីការទទួលខុសត្រូវរបស់ឃុំ/សង្កាត់ ។ ក្រុមប្រឹក្សាឃុំ/សង្កាត់ គ្មានអំណាចក្នុងវិស័យ ដូចជា ព្រៃឈើ ប្រៃសណីយ៍ ការពារជាតិ សន្តិសុខ ជាតិ រូបិយវត្ថុ គោលនយោបាយ ការបរទេស និងគោលនយោបាយសារពើពន្ធ ។

## ២. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់

ផ្អែកតាមបទបញ្ញតិនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ មានរចនាសម្ព័ន្ធជាក់លាក់មួយ:

- ផ្អែកតាមទំហំរបស់តំបន់ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ /សង្កាត់ ក្រុមប្រឹក្សាដែលមានសមាជិក ៥ ,៧, ៩, ១១ នាក់ ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សា ត្រូវកំនត់ដោយអនុក្រិត្យ ។
- ឃុំ /សង្កាត់នីមួយៗ មានមេឃុំ ឬចៅសង្កាត់ម្នាក់ ។ ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសអោយ ធ្វើជាមេឃុំ ឬចៅសង្កាត់ ។ មេឃុំ ចៅសង្កាត់ គឺជាប្រធានក្រុមប្រឹក្សាឃុំ .សង្កាត់ ។
- ក្រុមប្រឹក្សាឃុំ /សង្កាត់នីមួយៗមានប្រធានមួយរូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ /សង្កាត់ ។ ប្រធានក្រុមប្រឹក្សានេះ ក៏ជាមេឃុំ ឬចៅសង្កាត់ផងដែរ ។
- មេឃុំ ឬចៅសង្កាត់ នឹងមានជំនួយការ ២នាក់ គឺជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជំទប់ទី ២ ឬចៅសង្កាត់រងទី២ ។
- ក្រុមប្រឹក្សាឃុំ /សង្កាត់នីមួយៗ ត្រូវរៀបចំជ្រើសរើស អោយមានមេភូមិម្នាក់សំរាប់ភូមិនីមួយៗ ក្នុងឃុំ /សង្កាត់របស់ខ្លួន ។ មេភូមិគឺជាបណ្តាញផ្លូវការរវាងភូមិ និងក្រុមប្រឹក្សាឃុំ /សង្កាត់ ។
- មេឃុំ ឬចៅសង្កាត់ក៏អាចតែងតាំងផងដែរនូវគណៈកម្មាធិការផ្តល់យោល់ ។ គណៈកម្មាធិការនេះជាមនុស្សមួយក្រុមដែលមានគ្នាមិនតិចជាង ៣នាក់ ហើយផ្តល់យោបល់ និងជំនួយឧបត្ថម្ភដល់ក្រុមប្រឹក្សាពីបញ្ហាជាក់លាក់នានា ។ សមាជិកគណៈកម្មាធិការនេះ អាចជាសមាជិកក្រុមប្រឹក្សា អាចជាប្រជា

ពលរដ្ឋផ្សេងទៀតដែលមានសិទ្ធិបោះឆ្នោតផងដែរ ។ សមាជិកគណៈកម្មាធិការអាចជាស្ត្រី ឬបុរស ។ នៅពេលដែលសមាជិកក្រុមប្រឹក្សាបំពេញការងារជាសមាជិកគណៈកម្មាធិការ មេឃុំឬចៅសង្កាត់ត្រូវប្រឹងប្រែងអោយអស់លទ្ធភាពថាសមាសភាពរបស់គណៈកម្មាធិការនេះឆ្លុះបញ្ចាំងពីសមាសភាពនយោបាយនៅក្នុងក្រុមប្រឹក្សា ។

- ឃុំ /សង្កាត់ នីមួយៗមានស្មៀនមួយរូបដែលត្រូវបានតែងតាំង និងបំរើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋបាលក្រសួងក្រសួងមហាផ្ទៃ ។ ស្មៀនឃុំ /សង្កាត់ ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ.សង្កាត់ ។ នៅក្នុងការបំពេញមុខងាររបស់ខ្លួន ស្មៀនឃុំ /សង្កាត់ ត្រូវតែអព្យាក្រឹត និងមិនលំអៀង ។

- ប្រកាន់ឥរិយាបទអោយបានស្មើៗគ្នា ចំពោះប្រជាពលរដ្ឋទាំអស់នៅក្នុងឃុំ .សង្កាត់ សមាជិកក្រុមប្រឹក្សា និងក្រុមនយោបាយនៅក្នុងក្រុមប្រឹក្សា ឃុំ /សង្កាត់ ព្រមទាំងគណៈកម្មាធិការ ។ ប្រការនេះក៏មានន័យផងដែរថា ស្មៀនឃុំ /សង្កាត់ ត្រូវប្រកាន់ ឥរិយាបទអោយបានស្មើៗគ្នាចំពោះសមាជិកក្រុមប្រឹក្សា គ្រប់រូប ដោយមិនប្រកាន់គណបក្សនយោបាយ ។

- ក្រុមប្រឹក្សា ឃុំ.សង្កាត់ អាចផ្តល់ការងារដល់ បុគ្គលិកផ្សេងទៀត ដែលមិនស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលផងដែរ ។ បុគ្គលិកទាំងនេះ ត្រូវជួយការងាររបស់ក្រុមប្រឹក្សាឃុំ.សង្កាត់ដោយផ្អែក លើតម្រូវការនិងសេចក្តីសំរេចចិត្តជាក់លាក់របស់ក្រុមប្រឹក្សា ។ ការងាររបស់បុគ្គលិក អាចត្រូវពន្យាពេលបន្ត ដោយផ្អែកទៅតាមសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សានៅអណត្តិបន្ទាប់ ។ ស្ត្រី និងបុរសអាចទទួលបានការងារជាបុគ្គលិករបស់ក្រុមប្រឹក្សា ឃុំ /សង្កាត់ ។

- ស្ត្រី និងបុរស អាចទទួលបានមុខតំណែងដូចដែលបានលើកឡើងខាងលើ ។

# រចនាសម្ព័ន្ធ


ក្រុមប្រឹក្សាឃុំ / សង្កាត់
មេឃុំ/ចៅសង្កាត់
ជំទប់ទី ១ ឬចៅសង្កាត់រងទី១
ជំទប់ទី ២ ឬចៅសង្កាត់រងទី២
គណៈកម្មាធិការ
គណៈកម្មាធិការ
គណៈកម្មាធិការ
គណៈកម្មាធិការ
ស្មៀនឃុំ / សង្កាត់
ភូមិ
ភូមិ
ភូមិ
ភូមិ
ភូមិ

## ៣. តួនាទីនិងការទទួលខុសត្រូវរបស់អ្នកចូលរួមនានានៅក្នុងការ អភិវឌ្ឍន៍ឃុំ សង្កាត់

### ៣.១. តួនាទីនិងការទទួលខុសត្រូវរបស់អ្នកចូលរួមនានានៅក្នុងការ អភិវឌ្ឍន៍ឃុំ សង្កាត់

#### ក. សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់

* ធានាអោយបានថាក្រុមប្រឹក្សាប្រើប្រាស់ អំណាច តួនាទី និងមុខងារដូចមានចែង ក្នុងច្បាប់
* ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
* ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

#### ខ. មេឃុំ ចៅសង្កាត់

* ធានាអោយបានថា សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ.សង្កាត់ ត្រូវបានអនុវត្ត
* រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សា
* ផ្តល់យោបល់ និងជួយក្រុមប្រឹក្សាលើការងារកសាងផែនការហិរញ្ញវត្ថុ និងការអនុវត្តន៍ អំណាច តួនាទី និងមុខងារដោយក្រុមប្រឹក្សា ។
* ក្រុមប្រឹក្សាក៏អាចប្រគលភារកិច្ចផ្សេងទៀតដល់ មេឃុំ ឬចៅសង្កាត់ផងដែរ ។

#### គ. ប្រធានក្រុមប្រឹក្សា

* ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
* ធានាអោយបានថា ក្រុមប្រឹក្សាបានប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយខែ
* ធានាអោយបានថា កិច្ចប្រជុំត្រូវបានធ្វើឡើងស្របតាមបទបញ្ញត្តិសំរាប់កិច្ចប្រជុំ ។

#### ឃ. ជំទប់ទី១ ឬចៅសង្កាត់រងទី១

* បំពេញការងារជាមេឃុំ. ចៅសង្កាត់ ក្នុងករណីដែលមេឃុំ.ចៅសង្កាត់អវត្តមាន
* ជួយមេឃុំ .ចៅសង្កាត់លើការងារហិរញ្ញវត្ថុ និងសេដ្ឋកិច្ច
* មេឃុំ.ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី១ ឬចៅសង្កាត់រងទី១ ។

#### ង. ជំទប់ទី២ ឬចៅង្កាត់រងទី២

* បំពេញការងារមេឃុំ ឬចៅសង្កាត់ ក្នុងករណីដែលមេឃុំ .ចៅសង្កាត់ និងជំទប់ទី១ ឬចៅ សង្កាត់រងទី១ អវត្តមាន

* ជួយមេឃុំ ,ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និង សណ្ដាប់ធ្នាប់សាធារណៈ
* មេឃុំ ឬចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី ២ ឬចៅសង្កាត់រងទី ២

## ច_គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

* ផ្ដល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ,សង្កាត់ ដូចជាការ កសាងផែនការ និងថវិកា
* រាយការណ៍អំពីការវិវត្តន៍ការងារប្រចាំខែរបស់ខ្លួន
* ផ្ដល់យោបល់ពីវិធានការត្រូវអនុវត្ត ដែលពាក់ពន្ធ័ទៅនឹងការងារ ។

## ឆ_មេភូមិ

* ផ្ដល់មតិ ឬធ្វើជាតំណាងរបស់ភូមិនៅក្នុងក្រុមប្រឹក្សា
* ធានាអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅក្នុងភូមិ
* ធានាសណ្ដាប់ធ្នាប់សាធារណៈ ។

## ជ_ ស្មៀនឃុំ,សង្កាត់

* ត្រូវយល់ថា ថ្វីត្បិតស្មៀនឃុំ/សង្កាត់ ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តន៍ការងារ ស្មៀនឃុំ/សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំ របស់ក្រុមប្រឹក្សាឃុំ ,សង្កាត់ ។
* ស្មៀនឃុំ/សង្កាត់ជាអ្នកជួយក្រុមប្រឹក្សា និងជាតំណាងអោយការបំពេញតួនាទី និងមុខងារ ស្របទៅតាមតំរូវការ ផ្នែកច្បាប់
* បំពេញការងាររដ្ឋបាល
* ប្រឹងប្រែងដើម្បីធានាថាសេចក្ដីសំរេច និងការអនុវត្តន៍សេចក្ដីសំរេចចិត្តរបស់ក្រុមប្រឹក្សា ស្របទៅនឹង លក្ខខណ្ឌច្បាប់
* ជួយក្រុមប្រឹក្សាឃុំ /សង្កាត់ក្នុងការរៀបចំ និងការអនុវត្តន៍កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង គណៈកម្មាធិការ
* ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ឬរបស់គណៈកម្មាធិការ លើកលែងតែបានទទួល ការអនុញ្ញាតិអោយអវត្តមានជាមុនពីក្រុមប្រឹក្សា ឬមេឃុំ ឬចៅសង្កាត់

* ផ្តល់យោបល់អោយមេឃុំ /ចៅសង្កាត់ អំពីលក្ខខណ្ឌ និងនីតិវិធីសំរាប់ជ្រើសរើសមេភូមិ
* ជួយដល់ក្រុមប្រឹក្សាឃុំ.សង្កាត់ ដើម្បីបង្កើតអោយមានក្តារខៀនបិទប្រកាសមួយឬច្រើនកន្លែងដែលសាធារណៈជន ទូទៅអាចទទួលបានពត៌មានយ៉ាងហោចណាស់នៅក្នុងកំឡុងពេលម៉ោងធ្វើការធម្មតា ។ បិទបង្ហាញសេចក្តីជូនដំណឹងទាំងអស់ដែលក្រុមប្រឹក្សាមានបំណងផ្សព្វផ្សាយ ដូចជា សេចក្តីសំរេចរបស់ក្រុមប្រឹក្សា
* ជូនដំណឹងដល់អភិបាលខេត្ត /ក្រុងជាបន្ទាន់ ក្នុងករណីដែលក្រុមប្រឹក្សាបានសំរេចចាត់វិធានការវិន័យចំពោះសមាជិកក្រុមប្រឹក្សា ឬក៏បណ្តេញសមាជិកក្រុមប្រឹក្សាណាម្នាក់
* ជូនដំណឹងជាបន្ទាន់ដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងមេឃុំ .ចៅសង្កាត់ពីកាលបរិច្ឆេទ និងឈ្មោះរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ថ្មី ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសរើសចេញពីបញ្ជីបេក្ខជនមកជំនួសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែលបានបាត់បង់ពីដំណែង ។

## ៣.២. តួនាទី និងការទទួលខុសត្រូវរបស់អ្នកចូលរួមនានា និងស្ថាប័នសំខាន់ៗផ្សេងទៀត

### សាធារណជនទូទៅ ស្ត្រី និងបុរស_ចាស់ និងក្មេង

* បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់
* ចូលរួមនៅក្នុងកិច្ចការរបស់មេភូមិ និងឃុំ.សង្កាត់តាមរយៈនីតិវិធីដែលបានកំណត់ ដូចជានៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
* ទាមទារពត៌មាន ការឆ្លើយតប និងការទទួលខុសត្រូវពីក្រុមប្រឹក្សាឃុំ.សង្កាត់
* បង់ពន្ធ និងថ្លៃឈ្នួលផ្សេងៗ អនុលោមទៅតាមលក្ខខ័ណ្ឌច្បាប់
* ចូលរួមក្នុងការពិនិត្យតាមដានការអនុវត្តន៍គំរោងអភិវឌ្ឍន៍ ។
* អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន និងសមាគមន៍ និងក្រុមសហគមន៍នៅមូលដ្ឋាន
* គៀងគរសហគមន៍មូលដ្ឋាន
* ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់សហគមន៍មូលដ្ឋាន
* ស្វែងរកការគាំទ្រចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលខ្លួនជាតំណាង

* ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់លើការងារសំខាន់ៗ ទាក់ទងទៅនឹងការអភិវឌ្ឍន៍ភូមិ និងឃុំ .សង្កាត់ ។
* ធ្វើអោយ ប្រជាពលរដ្ឋមានការយល់ដឹងអំពីវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ។

## វិស័យឯកជន ដូចជា សហគ្រិនមូលដ្ឋានជាដើម

* សហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ .សង្កាត់ លើការងារទាក់ទងទៅនឹងការអភិវឌ្ឍន៍សេដ្ឋ-កិច្ច របស់ ឃុំ/សង្កាត់
* ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ឃុំ-សង្កាត់
* ផ្តល់ឱកាសបំរើការងារដល់ប្រជាពលរដ្ឋ ។

## សំនួរពិភាក្សាស្តីអំពីប្រពន្ធ័វិមជ្ឈការ

១- តើធាតុសំខាន់ៗ នៃប្រពន្ធ័វិមជ្ឈការមានអ្វីខ្លះ ?

២- តើតួនាទីសំខាន់ៗ ដែលក្រុមប្រឹក្សាឃុំ /សង្កាត់របស់អ្នកត្រូវបំពេញមានអ្វីខ្លះ ?

៣- តើការចូលរួមរបស់ប្រជាពលរដ្ឋ និងសារៈសំខាន់របស់វាក្នុងប្រពន្ធ័វិមជ្ឈការមានអ្វីខ្លះ ?

៤- តើឃុំ សង្កាត់ ត្រូវធ្វើដូចម្តេចដើម្បីឱ្យការអភិវឌ្ឍន៍របស់ខ្លួនឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ ?

៥- តើភារកិច្ចរបស់ អង្គការមិនមែនរដ្ឋាភិបាលក្នុងប្រពន្ធ័វិមជ្ឈការមានអ្វីខ្លះ ?

## ៤. ការកំណត់ទិសដៅសំរាប់វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់

វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ មានទិសដៅជាច្រើន

**ទិសដៅសំរាប់វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ គឺ :**

- ផ្តល់ឱកាសដល់ប្រជាជនសាមញ្ញអោយចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត ដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់គាត់ និងនៅក្នុងការកំណត់អនាគតរបស់គាត់ ។
- លើកកំពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាព រស់នៅ ។
- ធានាការអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមមានផ្តល់សេវា ជាមូលដ្ឋានផងដែរ ។

**៦ វិមជ្ឈការ គឺជាការផ្តល់ឱកាសជូនប្រជាពលរដ្ឋអោយចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសំរេចចិត្តផ្សេងៗ ដែលប៉ះពាល់មកលើជីវភាពរស់នៅរបស់ខ្លួន ។**

ជាមួយនឹងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅថ្នាក់ឃុំ/សង្កាត់ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងការទទួលខុសត្រូវក្នុងការដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរបស់ឃុំ/សង្កាត់ និងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន ។ ប្រជាពលរដ្ឋគ្រប់រូបរួមមានស្ត្រី បុរស មនុស្សចាស់ ក្មេង មានសិទ្ធិបញ្ចេញមតិ និងរួមចំណែក ។ ប្រជាពលរដ្ឋមានសិទ្ធិបង្ហាញពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួន ហើយចូលរួមតាមរយៈនីតិវិធី និង យន្តការដែលបានកំណត់ ។

មានមធ្យោបាយជាច្រើន ដើម្បីអោយប្រជាពលរដ្ឋបានចូលរួម ។ ប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើស រើសក្រុមប្រឹក្សាដែលគាត់គិតថាអាចតំណាងអោយផលប្រយោជន៍របស់គាត់បានប្រសើរបំផុត។ ប្រជាពលរដ្ឋ អាចបង្កើតទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សា ចំពោះការងារដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ឃុំ/សង្កាត់ ។ ប្រជាពលរដ្ឋអាចលើកឡើងពីបញ្ហា និងផលប្រយោជន៍របស់គាត់នៅក្នុងកិច្ចប្រជុំរបស់ភូមិ ។ ប្រជាពលរដ្ឋ អាចពិនិត្យតាមដានការអនុវត្តន៍គំរោងនៅក្នុងមូលដ្ឋានរបស់គាត់ ។ ប្រជាពលរដ្ឋមានសិទ្ធិទាមទារពត៌មាន ពីក្រុមប្រឹក្សា ដែលគាត់អាចទៅកាន់សាលាឃុំ,សង្កាត់ដើម្បីទទួលពត៌មាន ។ ការលើកកំពស់ ការចូលរួម របស់ប្រជាពលរដ្ឋ គឺជាភារកិច្ចយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ /សង្កាត់ ។ ការចូលរួមនេះជួយអោយក្រុម ប្រឹក្សាឃុំ /សង្កាត់ស្វែងយល់ពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយបង្កើតកម្មវិធី ដើម្បីដោះស្រាយសេចក្តីត្រូវការទាំងនោះ ។ ប្រសិនបើប្រជាពលរដ្ឋបានចូលរួម ប្រជាពលរដ្ឋមានអារម្មណ៍ ថា នឹងមានការទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**៦ វិមជ្ឈការ ត្រូវបានគេយល់ឃើញថា ជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការជំរុញអភិបាលកិច្ចល្អ ។ អភិបាលកិច្ចល្អ គឺជាការអនុវត្តន៍ស្របទៅនឹងទិដ្ឋភាពសំខាន់ៗ ចំនួនបួន :**

១. ក្រុមប្រឹក្សាឃុំ/សង្កាត់ និងសមាជិកក្រុមប្រឹក្សា ត្រូវដំណើរការអនុលោមទៅតាម ច្បាប់ ។ ច្បាប់បានបញ្ជាក់ពីអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សា និងសមាជិករបស់ក្រុមប្រឹក្សាទាំងនោះ ។

២. ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ ហើយត្រូវបានផ្តល់អំណាចជូនដោយប្រជាជននៅមូលដ្ឋាន ។ **ដូច្នេះអ្វីដែលក្រុមប្រឹក្សាឃុំ/សង្កាត់ធ្វើ គឺត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។** ប្រការនេះមានន័យថា ក្រុមប្រឹក្សា ត្រូវធ្វើផែនការណ៍អោយឆ្លើយតបទៅនឹងតំរូវការ

របស់ប្រជាពលរដ្ឋ ត្រូវផ្តល់ពត៌មានពីរបៀបប្រើប្រាស់ធនធានដែលខ្លួនមាន និងថាតើធនធានទាំងនេះពិតជាត្រូវបានប្រើប្រាស់ដើម្បីបំរើអោយផលប្រយោជន៍របស់ប្រជាពលរដ្ឋដែរ ឬទេ? ។

៣. ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវមានតម្លាភាពនៅក្នុងការងារទាំងអស់ដែលគាត់បំពេញ។ ប្រការនេះមានន័យថា ក្រុមប្រឹក្សាមិនត្រូវបិទបាំងចំពោះសាធារណជនឡើយ ។ ក្រុមប្រឹក្សាត្រូវជំរាបជូនសាធារណជនពីកិច្ចការនានា ដែលខ្លួនបានពិភាក្សា ឬពីសេចក្តីសំរេចចិត្តដែលខ្លួនបានធ្វើ ។ ក្រុមប្រឹក្សាត្រូវជំរាបជូនសាធារណជន និងទទួលមតិដែលផ្តល់ជូនសំរាប់ផែនការអភិវឌ្ឍន៍ និងថវិកាផងដែរ ។ កំណត់ហេតុនៃការប្រជុំ និងសេចក្តីសំរេចចិត្តដែលអនុម័តដោយក្រុមប្រឹក្សា ត្រូវតែបិទផ្សាយនៅលើក្តារខៀន ។

៤. ការចូលរួម ដូចដែលយើងបានលើកឡើងខាងលើ គឺជាសមាសធាតុយ៉ាងសំខាន់មួយទៀតនៅក្នុងអភិបាលកិច្ចល្អ ។

**ៜ ការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ គឺដើម្បីគាំទ្រការអភិវឌ្ឍន៍ប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាជាមូលដ្ឋាន ។ តើត្រូវគាំទ្រដោយវិធីណា ?**

ក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលស្ថិតនៅជិតប្រជាពលរដ្ឋ និងមូលដ្ឋានរបស់ខ្លួន អាចដឹងបានច្រើនពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។ ក្រុមប្រឹក្សាអាចរៀបចំកម្មវិធី ដើម្បីកែលំអរជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ដូច្នេះក្រុមប្រឹក្សាអាចប្រើប្រាស់ធនធានរបស់ខ្លួនយ៉ាងមានប្រសិទ្ធិភាព ។ ប្រជាពលរដ្ឋនៅមូលដ្ឋានអាចពិនិត្យមើលរបៀបប្រើប្រាស់ធនធានទាំងនោះពិតជាបំរើអោយផលប្រយោជន៍របស់ប្រជាពលរដ្ឋដែរ ឬទេ ? ។ ប្រសិនបើប្រជាពលរដ្ឋបានចូលរួមនៅក្នុងការកសាងផែនការរបស់គំរោងនៅក្នុងមូលដ្ឋានរបស់ខ្លួននោះគាត់នឹងមានអារម្មណ៍ថា មានការទទួលខុសត្រូវកាន់តែច្រើន ។

## ៥. បណ្តាញគាំទ្រដល់ឃុំ សង្កាត់

ការគ្រប់គ្រង រដ្ឋបាលឃុំ /សង្កាត់ គឺជាភារកិច្ចយ៉ាងលំបាក ។ ទោះជាយ៉ាងណា ក៏ដោយក៏ស្ថាប័ន និងអង្គការជាច្រើនកំពុងគាំទ្រក្រុមប្រឹក្សាឃុំ /សង្កាត់ ដែលនឹងធ្វើអោយវិមជ្ឈការទទួលបានជោគជ័យ ។

## ថ្នាក់ជាតិ

- **គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (គ.ឃ.ស) :** គ.ឃ.ស ជាគណៈកម្មាធិការ នៅថ្នាក់ជាតិ ដែលមានសមាជិកជាន់ខ្ពស់មកពីក្រសួងផ្សេងៗ ដែលត្រូវបានបង្កើតឡើង ជាពិសេស សំរាប់វិមជ្ឈការ ។ គណៈកម្មាធិការនេះមានការទទួលខុសត្រូវចំពោះការផ្តល់អនុសាសន៍ដល់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល ស្តីពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- **អនុគណៈកម្មការរបស់ គ.ឃ.ស :** នៅក្រោម គ.ឃ.ស មានអនុគណៈកម្មការជាច្រើនត្រូវបានបង្កើតឡើង ដែលត្រូវផ្តល់ការគាំទ្រនិងយោបល់ពីបញ្ហានានាពាក់ព័ន្ធនឹងអំណាច និងមុខងារ ការកសាងផែនការ និងការអភិវឌ្ឍន៍ កិច្ចការហិរញ្ញវត្ថុ ព្រំប្រទល់ និងនគររូបនីយកម្ម ព្រមទាំង ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ,សង្កាត់ ។ អនុគណៈកម្មការ ទាំងនេះ ត្រូវគាំទ្រដោយក្រុមការងាររបស់ខ្លួន ។
- **នាយកដ្ឋានរដ្ឋបាល មូលដ្ឋាន :** គឺជាសេនាធិការចំពោះការងារទាំងអស់ពាក់ព័ន្ធនឹងវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ,សង្កាត់នៅក្នុងក្រសួងមហាផ្ទៃ ។ ឧទាហរណ៍ : នាយកដ្ឋានរដ្ឋបាលមូលដ្ឋានទទួលខុសត្រូវចំពោះការពិនិត្យតាមដាន ការវាយតម្លៃ រាយការណ៍ អំពីសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងមន្ត្រីដែលបានតែងតាំង ដូចជាស្មៀន ។ នាយកដ្ឋាន រដ្ឋបាលមូលដ្ឋានត្រូវធានាថា វិធានការត្រឹមត្រូវសំរាប់ការបណ្តុះបណ្តាល និងកសាងសមត្ថភាពដែលរួមមានការអប់រំសាធារណជនត្រូវបានអនុវត្ត ។
- **ក្រសួងរបស់រាជរដ្ឋាភិបាលៈ** ក្រសួងរបស់រាជរដ្ឋាភិបាល ជួយក្នុងការរៀបចំគោលនយោបាយសំរាប់ វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ ។
- **អង្គការម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ :** មានការសន្យាដ៏ធំទូលាយក្នុងចំណោមអង្គការ ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើនសំរាប់ដំណើរការវិជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ។ ឧទាហរណ៍ : ជាក់ ស្តែងអង្គការទាំងនេះ នឹងគាំទ្រការ បណ្តុះបណ្តាល និងការកសាងសមត្ថភាព ។

## ថ្នាក់ខេត្ត និងស្រុក

- **រដ្ឋបាល ខេត្ត ក្រុង និងមន្ទីរនានា :** ក្រសួងមហាផ្ទៃបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវដល់អភិបាលខេត្ត/ក្រុង ដើម្បីគាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់ និងដើម្បីត្រួតពិនិត្យប្រតិបត្តិការរបស់ ក្រុមប្រឹក្សា ។ អភិបាលខេត្ត /ក្រុងត្រូវធានាថាមន្ទីរនានាត្រូវផ្តល់ការគាំទ្រ និងការណែនាំ ដល់ ក្រុមប្រឹក្សា ។
- **អង្គភាពរដ្ឋបាលមូលដ្ឋាននៅថ្នាក់ខេត្ត/ក្រុង និងស្រុក/ខ័ណ្ឌ :** ក្រសួងមហាផ្ទៃនឹងបង្កើតអោយមានអង្គភាពរដ្ឋបាលមូលដ្ឋាននៅថ្នាក់ខេត្ត /ក្រុង និងស្រុក /ខ័ណ្ឌ ដែលត្រូវផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សា ឃុំ/សង្កាត់ ។
- **រចនាសម្ព័ន្ធគាំទ្រពីកម្មវិធីអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល :** មានកម្មវិធីអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល ដែលមានសាខានៅថ្នាក់ស្រុកនិងខេត្ត ។
កម្មវិធី និងអង្គការទាំងនេះអាចគាំទ្រចំពោះការបណ្តុះបណ្តាល ឬការអប់រំសាធារណជនអំពីបញ្ហានានាពាក់ព័ន្ធនឹងក្រុមប្រឹក្សាឃុំ /សង្កាត់ ។

## ថ្នាក់ឃុំ/សង្កាត់

- **ស្មៀនឃុំ,សង្កាត់ :** ស្មៀនត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃអោយជួយការងាររបស់ ឃុំ/សង្កាត់ និងធានានិរន្តភាពការងាររដ្ឋបាល ។
- **រចនាសម្ព័ន្ធ គាំទ្រពីកម្មវិធីអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋានសមាគមន៍ និង ក្រុមសហគមន៍ :** អង្គការនៅមូលដ្ឋានអាចគាំទ្រក្រុមប្រឹក្សាឃុំ,សង្កាត់ក្នុងការគៀងគរសហគមន៍មូលដ្ឋាន ។

## ៦. ប្រតិភូកម្មភារកិច្ច និងការទទួលខុសត្រូវ :

ក្រុមប្រឹក្សាឃុំ,សង្កាត់មានភារកិច្ចជាច្រើនដែលត្រូវបំពេញ។ ប្រសិនបើមានការធ្វើប្រតិភូកម្មភារកិច្ច និងការទទួលខុសត្រូវអោយអ្នកដទៃនោះ មនុស្សជាច្រើនអាចចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍។ ប្រតិភូកម្មដែលមានលក្ខណៈប្រសើរនោះ គឺមានហេតុផលពីរយ៉ាង :

- ការងារជាច្រើនទៀតអាចត្រូវបំពេញដែលមានន័យថាការអភិវឌ្ឍន៍ជាវិជ្ជមាន កាន់តែច្រើនថែមទៀត កើតមានឡើងនៅក្នុងឃុំ ,សង្កាត់

- ប្រជាពលរដ្ឋកាន់តែច្រើន បានចូលរួមជាហេតុធ្វើអោយអ្នកទាំងនោះមានអារម្មណ៍ថាខ្លួនជាម្ចាស់ដំណើរការ ។

ប្រតិភូកម្មភារកិច្ចមិនមែនជាការងាយស្រួលឡើយ ព្រោះវាមិនគ្រាន់តែជាការផ្ទេរការងារដោយមិនបានពិចារណាល្អិតល្អន់នោះទេ ។ ប្រតិភូកម្ម គឺជាជំនាញមួយពិតប្រាកដដែលមនុស្សភាគច្រើនត្រូវរៀនសូត្រ ដើម្បីបំពេញការងារអោយកាន់តែប្រសើរ ។

តើត្រូវពិចារណាលើអ្វីខ្លះ ដើម្បីធានាអោយប្រតិភូកម្មប្រព្រឹត្តទៅល្អ ?

- កំណត់ភារកិច្ចអោយបាន ច្បាស់លាស់
  - តើភារកិច្ច ដែលលោកអ្នកពិតជាសុំអោយមនុស្សម្នាក់បំពេញមានអ្វីខ្លះ ?
  - តើទាមទារអោយមាន បទដ្ឋានអ្វី ?
  - តើលោក អ្នកបានផ្តល់ទៅអោយបុគ្គលនោះនូវពត៌មាន និងសម្ភារៈចាំបាច់ទាំងអស់ដើម្បីអោយពួកគេបំពេញការងារ ឬនៅ ?
  - កំណត់ពេលវេលាអោយបានច្បាស់លាស់ក្នុងការបំពេញការងារនោះអោយចប់ ។
- កំណត់អោយបានច្បាស់ពីអ្នកដែលត្រូវបំពេញភារកិច្ចនោះ
  - តើត្រូវការមនុស្សប៉ុន្មាននាក់ ដើម្បីបំពេញភារកិច្ចនោះ ?
  - តើត្រូវការចំណេះដឹង ជំនាញ ឬបទពិសោធន៍កំរិតណា ?
  - តើលោក អ្នកមានមនុស្សគ្រប់ចំនួន ដែលមានចំណេះដឹង បទពិសោធន៍ ឬជំនាញទៅតាមកំរិតដែលចង់បានដែរ ឬទេ ?
- ការត្រួតពិនិត្យ
  - តើនៅពេលណាដែលអ្នកទាំងនោះ ត្រូវរាយការណ៍ជូនលោក អ្នក ហើយរាយការណ៍ស្តីពីអ្វី ?
  - តើលោក អ្នកផ្តល់សេរីភាពអោយអ្នកទាំងនោះ ក្នុងការបំពេញការងារទៅតាមវិធីរបស់ខ្លួនក្នុងកំរិតណា ? ឬក៏លោក អ្នកចង់អោយពួកគេបំពេញការងារទៅតាមវិធីណាមួយផ្សេងទៀត ?
- ពិនិត្យមើលការយល់ដឹង
  - ធានាអោយបានថាបុគ្គលនោះដឹងយ៉ាងច្បាស់ពីអ្វីដែលត្រូវធ្វើ
  - អនុញ្ញាតិអោយពួកគេមានឱកាសសួរសំនួរ ។

# អភិបាលកិច្ចល្អ

## ១. និដ្ឋភាពទូទៅនៃអភិបាលកិច្ច

យោងតាមមាត្រា ៤១ ជំពូកទី ៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ចែងថា "រដ្ឋបាលឃុំ/សង្កាត់ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមាន ប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

## ១.១. និយមន័យ

អភិបាលកិច្ចត្រូវបានគេអោយនិយមន័យផ្សេងៗ គ្នាជាច្រើន អាស្រ័យនឹងស្ថានភាពជាក់ស្តែង ។ ជាសាមញ្ញ អភិបាលកិច្ចមានន័យថា : គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ។ ស្រដៀងគ្នានេះដែរ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP 1997) បានឱ្យនិយមន័យថា "អភិបាលកិច្ច ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស" ។

## ១.២. គោលបំណងនៃអភិបាលកិច្ច

គោលបំណងនៃអភិបាលកិច្ច គឺដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយ តាមមធ្យោបាយមួយដែលផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋ ។

ដើម្បីសំរេចបាននូវគោលបំណងខាងលើនេះ គេបានទទួលស្គាល់ជាទូទៅថា អភិបាលកិច្ច ទាមទារនូវការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាព ។ ចំនុចសំខាន់ៗ នៃការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាព មានដូចខាងក្រោម :

- ត្រូវមានសេវាថែទាំសុខភាពល្អសមស្រប និងគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋទាំងអស់ ដើម្បីជួយឱ្យពួកគេមានសុខភាពមាំមួន និងអាយុយឺនយូរ ។ នេះជាកត្តាដែលអាចធ្វើអោយប្រជាពលរដ្ឋមានសុខាមាលភាព និងថាមពលគ្រប់គ្រាន់ ដើម្បីចូលរួមបានយ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ។

- ត្រូវមានសេវាអប់រំល្អ សមស្រប និងគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីអោយពួកគេមានចំណេះដឹងនិងជំនាញពេញលេញក្នុងការបង្កើតឱកាសឪបានច្រើននិងសមស្របបំផុតសំរាប់ខ្លួន។

- ត្រូវបង្កើតឱកាសសំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាព សេដ្ឋកិច្ច និងមានការងារធ្វើដើម្បីរកប្រាក់ចំណូលគ្រប់គ្រាន់សំរាប់បំពេញតម្រូវការជាមូលដ្ឋាន ដូចជាស្បៀងអាហារ សំលៀក បំពាក់ ជំរកជាដើម សំរាប់ពួកគេផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគេ ។

ចំនុចសំខាន់ទាំងបីខាងលើនេះ ត្រូវបានអនុវត្តតាមមធ្យោបាយដែលធានាបាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការថែរក្សាបរិស្ថាន។

## ១.៣. តួអង្គសំខាន់ៗ ក្នុងអភិបាលកិច្ច

កាលពីមុនគេយល់ឃើញថាមានតែរដ្ឋាភិបាលមួយគត់ ដែលជាតួអង្គនៃអភិបាលកិច្ច ។ ប៉ុន្តែបច្ចុប្បន្ននេះ មានគំនិតថ្មីៗ ជាច្រើនបានបង្ហាញឱ្យឃើញថា ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ ។ ដូច្នេះ តួអង្គសំខាន់ក្នុងអភិបាលកិច្ចមានបី គឺ :

- រដ្ឋាភិបាល ជាតួអង្គសំខាន់ជាងគេ
- ផ្នែកឯកជន
- សង្គមស៊ីវិល

ឥទ្ធិពលនៃតួអង្គផ្នែកឯកជន និងសង្គមស៊ីវិល មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយអាស្រ័យលើល័ក្ខខ័ណ្ឌមួយចំនួន ដូចជាប្រព័ន្ធនយោបាយ លក្ខណះអំណោយផលខាងធនធានធម្មជាតិ ប្រជាពលរដ្ឋ ទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងកំរិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច....។ល។

ជាក់ស្តែង នៅក្នុងប្រទេសខ្លះ ផ្នែកឯកជន និងសង្គមស៊ីវិលមានអំណាច និងវិសាលភាពយ៉ាងធំធេង ប៉ុន្តែប្រទេសមួយចំនួនផ្សេងទៀត ផ្នែកឯកជន និងសង្គមស៊ីវិលនេះមានអំណាចឱកាស និងឥទ្ធិពលតិចតួចទៅលើកិច្ចការប្រទេសជាតិ ។

## ១.៤. អភិបាលកិច្ចល្អ

អភិបាលកិច្ចជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញបាននូវគោលការណ៍ទាំង ៨ ខាងក្រោមនេះ :



# ២. ការចូលរួម

ការចូលរួមក្នុងបរិបទអភិបាលកិច្ចល្អ សំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី ក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តនោះ ។

សារៈសំខាន់នៃការចូលរួម គឺដើម្បីធានាថា ពត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នា របស់ប្រជាពលរដ្ឋគ្រប់រូប ត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសំរេចចិត្ត ។

**ជាទូទៅការចូលរួមធ្វើឡើងតាម ២របៀប គឺការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈអ្នកតំណាង។**

## ២.១. ការចូលរួមដោយផ្ទាល់

ការចូលរួមដោយផ្ទាល់ មានន័យថា ជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯង នៅក្នុងដំ ណើរការនៃការធ្វើការសំរេចចិត្ត និងការអនុវត្តន៍សេចក្តីសំរេចចិត្តនោះ ។

ការចូលរួមដោយផ្ទាល់ របស់ប្រជាពលរដ្ឋនៅក្នុងសកម្មភាពអភិវឌ្ឍន៏ឃុំ/សង្កាត់ ដូចជា :

+ ការប្រជុំនៅ ថ្នាក់ភូមិ ក្នុងជំហ៊ានទី២ និងជំហ៊ានទី១១ នៃដំណើរការកសាងផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគ បីឆ្នាំ រំកិលឃុំ សង្កាត់ ។
+ ការកំណត់ ទីតាំងគំរោង
+ ការសិក្សា ផលប៉ះពាល់បរិស្ថាន
+ ការសិក្សា ដីធ្លី
+ ការប្រជុំដេញថ្លៃ គំរោង
+ ការតាមដានត្រួតពិនិត្យលើការអនុវត្តន៏កិច្ចសន្យាឃុំ សង្កាត់
+ ការប្រជុំរបស់ គណៈកម្មការគ្រប់គ្រងគំរោង
+ ការផ្តល់ពត៌មាននានា ជុំវិញការអនុវត្តន៏គំរោង....... ។ល ។

ការចូលរួមជាកំលាំងពលកម្ម និងធនធានរបស់ប្រជាពលរដ្ឋនៅក្នុងសកម្មភាពអភិវឌ្ឍន៏ឃុំ/សង្កាត់ របស់ខ្លួន ក៏ចាត់ទុកជាការចូលរួមដោយផ្ទាល់ដែរ ។

## ២.២. ការចូលរួមតាមរយៈអ្នកតំណាង

ការចូលរួមតាមរយៈអ្នកតំណាងមានន័យថា អ្នកតំណាងរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃ ការសំរេចចិត្ត និងការអនុវត្តន៍សេចក្តីសំរេចនោះ ។

អ្នកតំណាងត្រូវតែបំពេញតួនាទីជាអ្នកតំណាងអោយឆន្ទៈ និងផលប្រយោជន៏ប្រជាពលរដ្ឋដែលខ្លួនតំណាងអោយ ។

អ្នកតំណាងអោយប្រជាពលរដ្ឋ អាចត្រូវបានជ្រើសរើស តាមវិធីផ្សេងៗទៅតាមលក្ខណះ និងស្ថានភាពជាក់ស្តែង ដូចជា :

. ការតែងតាំង

. ការព្រមព្រៀងឯកភាពគ្នា

. ការបោះឆ្នោត

. ទំនៀមទំលាប់ ប្រពៃណី.......។ល។

ខាងក្រោមនេះ គឺជាអ្នកតំណាងរបស់ប្រជាពលរដ្ឋ ដែលចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍ឃុំសង្កាត់ ដូចជា :

. ក្រុមប្រឹក្សាឃុំ ,សង្កាត់

. គណៈកម្មាធិការកសាងផែនការ និងថវិកា

. គណៈកម្មការលទ្ធកម្ម

. គណៈកម្មការ គ្រប់គ្រងគំរោង

. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

. ក្រុមប្រើប្រាស់ និងថែទាំលទ្ធផលគំរោង

. គណៈកម្មការធនធានធម្មជាតិ

. អង្គការសហគមន៏មូលដ្ឋាន......។ល។

ក្នុងការជ្រើសរើសអ្នកតំណាង ត្រូវពិចារណាមួយចំនួនដូចខាងក្រោម :

- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយមានសមត្ថភាព និងលទ្ធភាពអាចបំពេញតួនាទីជាអ្នកតំណាងបាន ។
- ជាអ្នកតំណាងពិតប្រាកដឱ្យក្រុមជាក់លាក់ណាមួយ ។
- ជ្រើសរើស ឬតែងតាំងអ្នកតំណាងទៅតាមនីតិវិធីដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែង ។
- កំនត់ តួនាទី និងការទទួលខុសត្រូវអោយបាន ច្បាស់លាស់ ។

- មានផែនការការងារច្បាស់លាស់ ។
- មាននីតិវិធី ផ្លាស់ប្តូរសមាជិកអ្នកតំណាងច្បាស់លាស់ ។
- មានកម្មវិធីពង្រឹង សមត្ថភាព និងការគាំទ្រជាប្រចាំដល់អ្នកតំណាង ។

## ២.៣. វិធីសាស្ត្រដើម្បីជំរុញ ការចូលរួម

ដើម្បីជំរុញឱ្យសកម្មភាពចូលរួមកាន់តែមានភាពប្រសើរឡើង និងដើម្បីធានាឱ្យប្រជាពលរដ្ឋ និងអ្នកតំណាងរបស់ប្រជាពលរដ្ឋមានឱកាសចូលរួមយ៉ាងពេញលេញ ជាពិសេសតំណាងក្រុមអ្នកក្រីក្រ និងក្រុមងាយរងគ្រោះ ក្រុមប្រឹក្សាឃុំ សង្កាត់គួរពិចារណាលើចំនុចមួយចំនួន ដូចខាងក្រោម :

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់ និងភាពចាំបាច់នៃការចូលរួមរបស់ពួកគេ
- ផ្សព្វផ្សាយពត៌មានស្តីពីកិច្ចប្រជុំ និងពត៌មានផ្សេងៗ អោយបានទូលំទូលាយដល់ប្រជាពលរដ្ឋ
- កំនត់ពេលវេលា និងទីកន្លែងប្រជុំអោយបានសមស្រប
- បង្កបរិយាកាសនៃការប្រជុំឱ្យមានលក្ខណះជាចំហ មានការចូលរួមយ៉ាងផុសផុល និងសប្បាយរីករាយ
- រៀបចំទីកន្លែងប្រជុំ ប្រកបដោយផាសុខភាព
- រៀបចំអោយមានប្រព័ន្ធទទួល និងផ្តល់ពត៌មានដែលមានលក្ខណះងាយៗ និងអាចទទួលបាន
- បង្កើតទំនាក់ទំនងល្អ និងស្និតស្នាលជាមួយប្រជាពលរដ្ឋ ។

# ៣.នីតិរដ្ឋ

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អ ទាមទារអោយមានឯកសារក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ ដើម្បីបំរើ និងការពារផលប្រយោជន៍សាធារណៈ ហើយច្បាប់ទាំងនោះត្រូវតែបានអនុវត្តដោយមិនលំអៀង ។ លើសពីនេះទៀត ច្បាប់ទាំងនោះត្រូវតែការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិច ។

ដូច្នេះត្រូវមានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំ អៀង និងមិនពុករលួយ ។

**នីតិរដ្ឋក្នុងន័យ អភិបាលកិច្ចល្អ ផ្តោតជាសំខាន់ទៅលើ :**

- ឯកសារ ក្របខ័ណ្ឌច្បាប់
- ការអនុវត្តន៍ច្បាប់ ដោយមិនលំអៀង
- ការការពារ សិទ្ធិមនុស្ស

- តុលាការឯករាជ្យ និងយុត្តិធម៌
- សមត្ថកិច្ចពង្រឹង ការអនុវត្តន៍ច្បាប់ដោយមិនលំអៀង និងមិនពុករលួយ ។

## ៣.១. ឯកសារក្របខ័ណ្ឌច្បាប់

ឯកសារក្របខ័ណ្ឌច្បាប់ គឺជាលិខិតបទដ្ឋានគតិយុត្តិ ដែលរួមមានច្បាប់ អនុក្រឹត ប្រកាស សេចក្តីសំរេច សេចក្តីនែនាំ ដីកា និងលិខិតបទដ្ឋាននានា ។

ឯកសារក្របខ័ណ្ឌច្បាប់ មួយចំនួន ដែលទាក់ទងនឹងការបំពេញការងាររបស់ប្រឹក្សាឃុំ .សង្កាត់ រួមមាន :

- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់
- អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់
- ប្រកាសស្តីពីការកសាងផែនការអភិវឌ្ឍន៏ឃុំ សង្កាត់
- ប្រកាសស្តីពីការងារលទ្ធកម្មឃុំ/សង្កាត់
- សេចក្តីសំរេច ស្តីពី ការដាក់អោយប្រើប្រាស់សៀវភៅណែនាំ ស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ សង្កាត់.......។ល។

## ៣.២. ការអនុវត្តន៍ច្បាប់ ដោយមិនលំអៀង

ឯកសារក្របខ័ណ្ឌច្បាប់ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ។ រាល់ការអនុវត្តន៏ ត្រូវតែធ្វើឡើងដោយសមស្របតាមឯកសារក្របខ័ណ្ឌច្បាប់ទាំងនោះយ៉ាងពេញលេញ ត្រឹមត្រូវ យុត្តិធម៌ និងមិនលំអៀង ។

ឧទាហរណ៏: ការតែងតាំងសមាជិកគណៈកម្មការនានា ការជ្រើសរើសទីតាំងគំរោង ការអនុវត្តន៍កិច្ចលទ្ធកម្ម ការអនុវត្តន៏គំរោងឃុំ,សង្កាត់ ជាដើម ត្រូវតែធ្វើឡើងទៅតាមគោលការណ៏ណែនាំដែលបានកំនត់ ។

## ៣.៣. ការការពារសិទ្ធិមនុស្ស

សិទ្ធិមនុស្ស គឺជាសេចក្តីត្រូវការចាំបាច់របស់មនុស្សគ្រប់ៗរូប ដែលមានតាំងពីកំណើត ដើម្បីទាមទារ នូវអ្វីៗ ដែលធ្វើអោយមនុស្សរស់នៅប្រកបដោយវិចារណញ្ញាណ និងសេចក្តីថ្លៃថ្នូរ ។

នៅក្នុងសេចក្តីប្រកាស ស្តីពីការកសាងផែនការអភិវឌ្ឍន៏ឃុំ /សង្កាត់បានចែងអំពីនីតិវិធីដើម្បីធានាឱ្យមានការចូលរួមរបស់ក្រុមជនជាតិដើមភាគតិច ឬស្ត្រី និងក្រុមជនងាយរងគ្រោះ ។ ជាមួយគ្នានោះដែរ ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ/សង្កាត់ ត្រូវបានគេលើកមកពិចារណាជាពិសេសផងដែរ ។

នៅក្នុងសៀវភៅណែនាំ ស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ/សង្កាត់ បានចែងយ៉ាងច្បាស់អំពីនីតិវិធី នៃការសិក្សាដីធ្លី ដែលក្នុងនោះបានផ្តល់សិទ្ធិដល់ម្ចាស់ដី ក្នុងការសំរេចផ្តល់ ឬមិនផ្តល់ដី និងទ្រព្យសម្បត្តិ របស់ខ្លួនទៅអោយគំរោង ដោយគ្មានសំណងទូទាត់ ។

## ៣.៤. តុលាការឯករាជ្យ និងយុត្តិធម៌

ជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់តែងតែប្រឈមមុខនឹងបញ្ហាដែលកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន ។ បញ្ហាទាំងនោះមានដូចជា ជម្លោះដីធ្លី អំពីហឹង្សាក្នុងគ្រួសារឬជម្លោះជាច្រើនរូបភាពផ្សេងទៀត ។

ក្រុមប្រឹក្សាឃុំ/សង្កាត់ជាអ្នកដែលចូលរួមសំរុះសំរួលនូវរាល់បញ្ហាជម្លោះទាំងនោះដំបូងគេ។ បើករណី ជម្លោះនោះមិនអាចសំរុះសំរួលបាន ជម្លោះនោះ ត្រូវដោះស្រាយតាមនីតិវិធីតុលាការ ។

តុលាការមានតួនាទីកាត់ក្តីជម្លោះនោះ ដោយយុត្តិធមិ និងមិនលំអៀង ។ ដូច្នេះ តុលាការឯករាជ្យ និងយុត្តិធមិ ជាយន្តការស្នូលមួយ ក្នុងការជំរុញអោយមានការគោរព និងអនុវត្តច្បាប់ ។

## ៣.៥. សមត្ថកិច្ចពង្រឹង ការអនុវត្តន៍ច្បាប់ មិនលំអៀង និងមិនពុករលួយ

ជាការពិតណាស់ ក្រុមប្រឹក្សាឃុំ,សង្កាត់ មានតួនាទីត្រឹមតែធ្វើការសំរុះសំរួល និងរាយការណ៍ទៅ សមត្ថកិច្ចទទួលខុសត្រូវអំពីបញ្ហា ឬជម្លោះដែលកើតឡើង ។ សមត្ថកិច្ចទទួលខុសត្រូវអនុវត្តច្បាប់ ដោយមិន លំអៀង និងមិនពុករលួយ គឺជាការរួមចំណែកយ៉ាងខ្លាំង ក្នុងអភិបាលកិច្ចល្អ ។

# ៤. តម្លាភាព

តម្លាភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថា រាល់ការសំរេចចិត្ត និងការអនុវត្តន៍សេចក្តីសំរេចចិត្ត នោះត្រូវធ្វើឡើង :

. ដោយអនុលោមទៅតាម ច្បាប់ និងបទបញ្ញត្តិនានា ។

. ពត៌មានពាក់ព័ន្ធនឹងការសំរេចចិត្ត និងការអនុវត្តន៍សេចក្តីសំរេចចិត្ត ត្រូវផ្សព្វផ្សាយជាចំហរ តាម រយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបាន ជាពិសេសចំពោះអ្នកដែលទទួលរងគ្រោះនូវផលប៉ះពាល់ពីការសំ រេចចិត្ត និងការអនុវត្តន៍សេចក្តីសំរេចចិត្តទាំងនោះ ។

. ពត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់ ។

**ឧទាហរណ៍១ :** រាល់ការធ្វើសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ,សង្កាត់ ត្រូវបានអនុលោម តាមបទបញ្ជាផ្ទៃក្នុង ដូចជា :

- ប្រជុំយ៉ាងតិចម្តងក្នុង ១ខែ និងអាចមានការប្រជុំពិសេសថែមទៀត

- រាល់កិច្ចប្រជុំត្រូវធ្វើឡើងជាសាធារណៈ

- សមាជិកក្រុមប្រឹក្សាឃុំ .សង្កាត់ត្រូវបានអញ្ជើញរយៈពេល បីថៃមុនពេលប្រជុំ ។

- កម្មវិធីប្រជុំរបស់ក្រុមប្រឹក្សាឃុំ /សង្កាត់ត្រូវផ្សព្វផ្សាយជាសាធារណៈ ដល់ប្រជាពលរដ្ឋនៅក្នុងឃុំ/ សង្កាត់របស់ខ្លួន ។

- របៀបវារៈប្រជុំត្រូវបានរៀបចំជាលាយល័ក្ខណ៍អក្សរ ។ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងប្រជាពលរដ្ឋ អាចស្នើសុំបន្ថែមចំណុចផ្សេងៗ ទៅក្នុងរបៀបវារៈនេះ ។

- ស្មៀនឃុំ សង្កាត់ និងអ្នកចូលរួមផ្សេងៗទៀត ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ .សង្កាត់មានសិទ្ធិបញ្ចេញមតិដោយសេរី ប៉ុន្តែពុំមានសិទ្ធិសំរេចនោះទេ ។

- រាល់ការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ /សង្កាត់ត្រូវផ្អែកតាមមតិភាគច្រើនដាច់ខាត ។

- រាល់ការសំរេចរបស់ក្រុមប្រឹក្សាឃុំ.សង្កាត់ត្រូវកត់ត្រានៅក្នុងកំណត់ហេតុប្រជុំនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**ឧទាហរណ៍២ :** កិច្ចលទ្ធកម្មគំរោងមូលនិធិឃុំ /សង្កាត់ ត្រូវធ្វើឡើងតាមនីតិវិធីដែលមានចែងនៅក្នុង សៀវភៅណែនាំស្តីអំពីការអនុវត្តន៍គំរោងមូលនិធិឃុំ /សង្កាត់ ដូចជា :

- គណៈកម្មការលទ្ធកម្ម ត្រូវបានបង្កើតឡើង និងបំពេញមុខងារស្របតាមការណែនាំ

- ឯកសារពាក់ព័ន្ធនឹងការដេញថ្លៃ ត្រូវផ្សព្វផ្សាយជាសាធារណៈ

- កិច្ចប្រជុំលទ្ធកម្មត្រូវរៀបចំឡើងជាសាធារណៈ

- លទ្ធផលនៃការដេញថ្លៃ ត្រូវប្រកាសជាសាធារណៈ ។

**ឧទាហរណ៍៣ :** ការប្រើប្រាស់ថវិកាមូលនិធិឃុំ /សង្កាត់ ត្រូវអនុវត្តទៅតាមគោលការណ៍ណែនាំដូចជា :

- ត្រូវរៀបចំគំរោងថវិកាប្រចាំឆ្នាំ ដោយមានការចូលរួម

- ត្រូវអនុវត្តចំណាយ ចំណូលទៅតាមនីតិវិធីដែលបានកំណត់

- ត្រូវចុះបញ្ជីការគណនេយ្យឱ្យបានច្បាស់លាស់

- ត្រូវធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុជាសាធារណៈ ។

# ៥. ការព្រមព្រៀងឯកភាពគ្នា

ការព្រមព្រៀងឯកភាពគ្នា ក្នុងន័យអភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗ គ្នានៅក្នុងសង្គម ហើយឈានទៅរកការសំរេចចិត្តដោយមានការព្រមព្រៀងឯកភាពគ្នាលើជំរើស និងវិធីសាស្ត្រល្អណាមួយដែលបំរើផលប្រយោជន៍រួម សំរាប់សហគមន៍ទាំងមូល ។

## ៥.១. ភាពផ្សេងៗគ្នានៅក្នុងសង្គម

ក្រុមមនុស្សក្នុងសង្គម តែងតែមានគំនិត បញ្ហា តម្រូវការ អាទិភាព ដំណោះស្រាយ ការពេញចិត្ត ចំណេះដឹង និងការយល់ឃើញផ្សេងៗ គ្នា ។ ហេតុដូច្នេះ ការពិចារណាឱ្យបានយ៉ាងទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍នៃអ្នកពាក់ព័ន្ធផ្សេងៗ គ្នាទាំងនោះ ត្រូវគិតដល់ចំណុចមួយចំនួន ដូចជា :

. **ស្ថានភាព** រួមមានដូចជា បញ្ហាតម្រូវការ អាទិភាព ភេទ អាយុ ឋានៈក្នុងសង្គម មុខរបរ..... ។ល។

. ក្រុមជនងាយរងគ្រោះ រួមមានដូចជា អ្នកជំងឺអេដស៍ ជនពិការ អ្នកប្រើប្រាស់គ្រឿងញៀន កុមារកំព្រា ស្ត្រីរកស៊ីផ្លូវភេទ ទុរគតជន ចាស់ជរា..... ។ល។

. ប្រវត្តិសាស្ត្រ : ប្រវត្តិរបស់ជនជាតិនីមួយៗ

. វប្បធម៌ ទំនាមទំលាប់ប្រពៃណី ដូចជាភាសា ពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យប្រពៃណីផ្សេងៗ ទៀត... ។ល។

. ជំនឿ សាសនា ដូចជា សាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រីស្ត.... ។ល។

. គណបក្សនយោបាយ ដូចជាគណបក្សប្រជាជន គណបក្សសមរង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច.... ។ល។

. ក្រុមជាតិសាសន៍ ដូចជា គួយ ភ្នង ចារាយ គ្រឹង កាចក់ ចិន ចាម វៀតណាម.... ។ល។

## ៥.២. គោលការណ៍ណែនាំសំរាប់សំរបសំរួលអោយមានការព្រមព្រៀងឯកភាពគ្នា

ក). លក្ខខ័ណ្ឌនៃការព្រមព្រៀងឯកភាពគ្នា

លក្ខខ័ណ្ឌនៃការព្រមព្រៀងឯកភាពគ្នា រួមមាន :

. ការព្រមព្រៀងគ្នាប្រកបដោយសុខដុមរមនា

. ការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងអស់

. ការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត

. ការយល់ដឹងអំពីគ្នាទៅវិញទៅមក រវាងក្រុមពាក់ព័ន្ធទាំងអស់ ។

**ខ). ដំណើរការនៃការព្រមព្រៀងឯកភាពគ្នា**

ខាងក្រោមនេះជាការណែនាំខ្លះៗ ដើម្បីធ្វើការសំរុះសំរួលអោយមានការព្រមព្រៀងឯកភាពគ្នា :

. រៀបចំអោយមានការជួបជុំគ្នារវាងក្រុមពាក់ព័ន្ធទាំងអស់

. ស្វែងយល់ចិត្តគ្នាទៅវិញទៅមករវាងក្រុមអ្នកពាក់ព័ន្ធទាំងអស់ និងបង្កើតការយោគយល់គ្នា

. ពិភាក្សាជាមួយក្រុមពាក់ព័ន្ធទាំងអស់ អំពីផលប្រយោជន៍ និងបង្កើតជំរើសនានា

. សំរុះសំរួលដើម្បីសំរេចយកជំរើសល្អមួយដែលបំរើនូវផលប្រយោជន៍រួម ដោយមានការព្រមព្រៀងឯកភាពគ្នាប្រកបដោយសុខដុមរមនា ។

## ៦. សមធម៌

សមធមិនៅក្នុងន័យអភិបាលកិច្ចល្អមានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់នៅក្នុងសហគមន៍ ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់ក្នុងការចូលរួមបញ្ចេញយោបល់ លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលំអរ និងថែរក្សាសុខាមាលភាពរបស់ពួកគេ ។ លើសពីនេះទៀតពួកគេមានអារម្មណ៍ថា ខ្លួនគឺជាសមាជិកពិតប្រាកដរបស់សង្គម និងមិនត្រូវបានសង្គមបោះបង់ចោលនោះទេ ។

សុខាមាលភាពរបស់សមាជិក ឬក្រុមនីមួយៗ គឺសុខាមាលភាពរបស់សង្គមទាំងមូល ។ ដូចនេះដំណើរការនៃការសំរេចចិត្ត និងការអនុវត្តន៍សេចក្តីសំរេចចិត្តប្រកបដោយសមធមិ និងធ្វើអោយគ្រប់សមាជិកទាំងអស់នៅក្នុងសង្គម មានអារម្មណ៍ថា ពួកគេម្នាក់ៗ គឺជាសមាជិកពិតប្រាកដរបស់សង្គម និងបានចូលរួមចំណែកនៅក្នុងដំណើរការអភិវឌ្ឍន៍សង្គមនោះ ។ លើសពីនេះទៅទៀត មិនមានសមាជិកណាម្នាក់ គិតថាខ្លួនគេត្រូវបានសង្គមបោះបង់ចោលនោះឡើយ ។

សុខាមាលភាព ផ្តោតជាសំខាន់ទៅលើភាពសប្បាយ ភាពសុខស្រួល សុវត្ថិភាព សន្តិសុខ សុខភាពល្អ...។ល។ សុខាមាលភាពរបស់មនុស្សម្នាក់ៗ មិនគ្រាន់តែគិតលើផ្នែករូបរាងកាយប៉ុណ្ណោះទេ តែត្រូវគិតដល់ ផ្នែកជំនឿ សាសនា ស្មារតី ផ្លូវចិត្ត អារម្មណ៍ ព្រមទាំងភាពគ្រប់គ្រាន់ក្នុងជីវភាពរស់នៅ ផងដែរ ។

ប្រសិនបើប្រជាពលរដ្ឋទាំងអស់បានចូលរួមដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន ក្នុងដំណើរការ និងអនុវត្ត សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ /សង្កាត់ ហើយសេចក្តីសំរេចចិត្តនោះ បានបំរើផល ប្រយោជន៍ រួមសំរាប់សហគមន៍ទាំងមូល នោះប្រជាពលរដ្ឋ និងមានការពេញចិត្ត និងរីករាយជាមួយនឹង ការបំពេញមុខ ងាររបស់ក្រុមប្រឹក្សាឃុំ /សង្កាត់ តែប្រសិនបើប្រជាពលរដ្ឋមិនត្រូវបានផ្តល់ឱកាសឱ្យ ចូលរួមក្នុងដំណើរការ និងអនុវត្តសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ ,សង្កាត់ ហើយរាល់ការសំរេចចិត្តនោះ មិនបានបំរើផលប្រយោជន៍រួមដល់សហគមន៍ទាំងមូល នោះប្រជាពលរដ្ឋនឹងមានអារម្មណ៍ថា ក្រុមប្រឹក្សា ឃុំ/សង្កាត់ មិនបានយកចិត្តទុកដាក់ចំពោះពួកគេ ហើយពួកគេនឹងមិនយល់ស្រប ឬមិនសប្បាយចិត្តនឹង ការសំរេចចិត្តរបស់ក្រុម ប្រឹក្សាឃុំ ,សង្កាត់ឡើយ ។

ជាក់ស្តែងដើម្បីធានាឱ្យមានសមធម៌នៅក្នុងការងារអភិវឌ្ឍន៍ ឃុំ /សង្កាត់ ក្រុមប្រឹក្សាឃុំ /សង្កាត់ បាន :

. បង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

. បង្កើតអ្នកទទួលបន្ទុកការងារស្ត្រី និងកុមារ

. បង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា

. អនុញ្ញាតឱ្យតំណាងជនជាតិដើមភាគតិច ចូលរួមនៅក្នុងការប្រជុំគណៈកម្មាធិការកសាងផែនការ និងថវិកា.....។ល។

### សំនួរពិភាក្សា ស្តីពី អភិបាលកិច្ចល្អ

១. តើធាតុសំខាន់ៗ នៃអភិបាលកិច្ចល្អមានអ្វីខ្លះ ?

២. ហេតុអ្វីបានជាយើងត្រូវការអភិបាលកិច្ចមូលដ្ឋាន ?

៣. តើត្រូវធ្វើដូចម្តេចដើម្បីអោយមានអភិបាលកិច្ចល្អ ?

៤. តើគោលបំណងរបស់ អភិបាលកិច្ចល្អ មានអ្វីខ្លះ ?

៥. ហេតុអ្វីចាំបាច់ត្រូវមានស្ត្រីចូលរួមក្នុងការអភិវឌ្ឍន៍ ឃុំ ,សង្កាត់ ?

## ៧. ប្រសិទ្ធិភាពខ្ពស់

ប្រសិទ្ធភាពខ្ពស់ក្នុងន័យអភិបាលកិច្ចល្អមានន័យថាជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការ ប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណ

ច្រើន អាចបំរើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតាមតម្រូវការពិតរបស់សង្គម ។ គោលគំនិតនៃប្រសិទ្ធភាពខ្ពស់នៅក្នុងបរិបទអភិបាលកិច្ចល្អ ក៏បានបញ្ចូលផងដែរ ចំពោះការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន ។

ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តន៍ ក្រុមប្រឹក្សាឃុំ,សង្កាត់ត្រូវពិចារណាលើចំនុចមួយចំនួនដូចខាងក្រោម :

. ការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ

. ការអនុវត្តន៍សកម្មភាពដែលជាអទិភាពខ្ពស់

. ជៀសវាងអនុវត្តនូវការិយាធិបតេយ្យ

. ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ

. គ្មានអំពើពុករលួយ

. ការសំរេចចិត្តតាមបែបវិមជ្ឈការ.....។ល។

## ៧.១. ការប្រើប្រាស់ធនធានបានត្រឹមត្រូវ

កាលណាប្រើប្រាស់ធនធានបានត្រឹមត្រូវ នាំអោយមានប្រសិទ្ធភាពខ្ពស់ ។ ធនធានទាំងនោះមានដូចជាធនធានមនុស្ស ធនធានថវិកា សម្ភារ ពេលវេលា....។ល។

**ឧទាហរណ៍១ :** ការរៀបចំបុគ្គលិកតាមជំនាញរបស់គេ គឺជាការប្រើប្រាស់ធនធានមនុស្សបានត្រឹមត្រូវ និងអាចមានប្រសិទ្ធខ្ពស់ ព្រោះកាលណាបុគ្គលិកធ្វើការចំជំនាញរបស់គេ នោះគេអាចធ្វើការបានល្អត្រឹមត្រូវ និងបានរហ័សទៀតផង ។ ទន្ទឹមនោះចំណេះដឹងរបស់គេនឹងមានការរីកចំរើនកាន់តែខ្លាំង។

**ឧទាហរណ៍២ :** ប្រសិនបើក្រុមប្រឹក្សាឃុំ,សង្កាត់ ត្រូវការទិញម៉ាស៊ីនភ្លើងមួយគ្រឿងសំរាប់ប្រើប្រាស់ក្នុងការិយាល័យ នោះការគិតជាចំបងមិនគ្រាន់តែលើតម្លៃម៉ាស៊ីនភ្លើងប៉ុណ្ណោះទេ តែក៏រឹតនៃការស៊ីប្រេង ភាពអាចរកបាននៃគ្រឿងបន្លាស់ និងតំលៃនៃការថែទាំក៏ជាចំនុចដែលត្រូវពិចារណាជាចាំបាច់ផងដែរ។

## ៧.២. ការអនុវត្តន៍សកម្មភាពដែលជាអទិភាពខ្ពស់

ការអនុវត្តន៍សកម្មភាពដែលជាអទិភាពខ្ពស់មានន័យថា រាល់តម្រូវការពិតប្រាកដ ចាំបាច់ និងបន្ទាន់បំផុតរបស់ប្រជាពលរដ្ឋទូទៅ ត្រូវបានយកមកពិចារណា និងដោះស្រាយមុនគេ ។

ប្រសិនបើគំរោងដែលជាអទិភាពខ្ពស់របស់អ្នកភូមិ ត្រូវបានអនុវត្តនោះ អ្នកភូមិនឹងចូលរួមក្នុងការអនុវត្តន៍គំរោងនោះ ហើយមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការថែទាំសមិទ្ធិផលទាំងអស់នោះទៀតផង ។ លើសពី

នេះទៀត អ្នកភូមិនឹងពេញចិត្តបង់ទុនចូលរួម ព្រោះគំរោងនេះបានឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ ពួកគេ ។

## ៧.៣.ជៀសវាងអនុវត្តការិយាធិបតេយ្យ

ដើម្បីអោយការអនុវត្តន៍សកម្មភាពមានប្រសិទ្ធភាពខ្ពស់ ត្រូវជៀសវាងនូវការិយាធិបតេយ្យ ព្រោះបើមិនដូច្នោះទេ មានសកម្មភាពជាច្រើនតែងតែពន្យារជាបន្តបន្ទាប់ ដោយសារតែទំរង់បែបបទច្រើនពេក រង់ចាំការពិនិត្យឯកសារ និងការអនុម័តយល់ព្រមរបស់អ្នកដឹកនាំពីម្នាក់ទៅម្នាក់ ឬពីមួយថ្នាក់ទៅមួយថ្នាក់ ឬការបញ្ជូនឯកសារប្រឡប់ចុះឡើងច្រើនសារពេក ។ ជាលទ្ធផល ការអនុវត្តគំរោងមិនបានស្របតាមផែនការថវិកាមិនបានចំណាយទាន់ពេលវេលាហើយតំរូវការរបស់ប្រជាពលរដ្ឋ ក៏មិនបានឆ្លើយតបនឹងដោះស្រាយ ទាន់ពេលវេលាផងដែរ ។

## ៧.៤. ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ

ការគិតគូររយៈពេលវែងទៅលើការប្រើប្រាស់ធនធានធម្មជាតិមានន័យថា រាល់ការសំរេចចិត្តក្នុងការប្រើប្រាស់ធនធានធម្មជាតិត្រូវគិតដល់តម្លៃនៃធនធាន និរន្តរភាពនៃការប្រើប្រាស់ ផលប៉ះពាល់ដល់បរិស្ថាន និងកំរិតនៃភាពអាចដុះដាលឡើងវិញបាននូវធនធានធម្មជាតិទាំងនោះ ។

**ឧទាហរណ៍ :** ឃុំមានបឹងតូចមួយ

- ប្រជាពលរដ្ឋមួយចំនួនបានរកត្រីនៅក្នុងបឹងនេះ ដើម្បីចិញ្ចឹមជីវិត ។
- ប្រជាពលរដ្ឋមួយចំនួនបានប្រើប្រាស់បឹងនេះសំរាប់ចិញ្ចឹមសត្វទា និងសត្វគោក្របី ។
- ប្រជាពលរដ្ឋមួយចំនួនទៀត ចង់បូមទឹកបឹងដើម្បីស្រោចស្រពស្រូវ និងចំការបន្លែ ។

ប្រសិនបើការបូមទឹកបឹងសំរាប់ស្រោចស្រពច្រើនពេក បឹងនេះនឹងលែងមានត្រី និងលែងមានទឹកសំរាប់ចិញ្ចឹមទា និងសត្វគោក្របី ។ ក្រុមប្រឹក្សាឃុំ/ សង្កាត់ ព្យាយាមធ្វើផែនការ ដើម្បីប្រើប្រាស់បឹងនេះសំរាប់បំរើអោយផលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់រូប ។

រាល់ការសំរេចចិត្ត ដែលធានាអោយមាននិរន្តរភាពនៃការប្រើប្រាស់ទឹកបឹងជាការសំរេចចិត្តមួយ ដែលល្អ និងបានគិតគូររយៈពេលវែងនៃការប្រើប្រាស់ធនធានធម្មជាតិ ។

## ៧.៥. គ្មានអំពើពុករលួយ

គ្មានអំពើពុករលួយនៅក្នុងការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាឃុំ.សង្កាត់ គឺជាកត្តាមួយសំខាន់ណាស់ក្នុងការអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទទួលបាននូវទំនុកចិត្តពីប្រជាពលរដ្ឋ ។ បើ

មានអំពើពុករលួយនៅក្នុងការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាឃុំ,សង្កាត់នោះនឹងនាំឱ្យការអនុវត្តន៍ការងារគ្មានប្រសិទ្ធភាព និងមិនត្រូវបានទទួលនូវការគោរពស្រឡាញ់ពីប្រជាពលរដ្ឋឡើយ ។

**ឧទាហរណ៍ :** បើមានអំពើពុករលួយកើតឡើងនៅក្នុងការប្រើប្រាស់មូលនិធិឃុំ/សង្កាត់ រវាងក្រុមប្រឹក្សាឃុំ /សង្កាត់ជាមួយអ្នកដេញថ្លៃគំរោង នោះនឹងធ្វើអោយតម្លៃគំរោងឡើងខ្ពស់ គុណភាពគំរោងអន់ និង បាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋ ។ លើសពីនេះទៀត ប្រជាពលរដ្ឋនឹងលែងចូលរួមជាមួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងសកម្មភាពអភិវឌ្ឍន៍នានា ។

## ៧.៦. ការសំរេចចិត្តតាមបែបទិមជ្ឈការ

ក្រុមប្រឹក្សាឃុំ/សង្កាត់រស់នៅ និងធ្វើការផ្ទាល់ជាមួយប្រជាពលរដ្ឋពួកគាត់អាចដឹងអំពីបញ្ហាតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ និងអាចរកដំណោះស្រាយណាមួយដែលមានប្រសិទ្ធភាពខ្ពស់ និងសមស្របតាមស្ថានភាព ជាក់ស្តែងក្នុងឃុំ /សង្កាត់របស់ខ្លួន ។

ដូចនេះការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋ អាចមានប្រសិទ្ធភាពខ្ពស់ជាងអ្នកមកពីខាងក្រៅ ឬអ្នកដទៃទៀត។

# ៨. គណនេយ្យភាព

គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាការអនុវត្តន៍តួនាទី និងភារកិច្ច នៅក្នុងដំណើរការ និងអនុវត្តសេចក្តីសំរេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសំរេច និងអនុវត្ត ។

គណនេយ្យភាពគឺមិនត្រឹមតែជាការទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់ដែលបានស្នើសុំឱ្យធ្វើអ្វីមួយនោះទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាពដែលបានអនុវត្តចំពោះមុខ អ្នកពាក់ព័ន្ធទាំងអស់ផងដែរ ។

មិនមែនមានតែស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ដែលត្រូវមានគណនេយ្យភាព អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជនក៏ត្រូវមានគណនេយ្យភាពជាសាធារណៈ ចំពោះអ្នកដែលពាក់ព័ន្ធទាំងអស់របស់ខ្លួនផងដែរ ពិសេសចំពោះអ្នកដែកទទួលរងនូវផលប៉ះពាល់អំពីការសំរេចចិត្ត ។

គណនេយ្យភាពរួមមាន គណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ និងគណនេយ្យភាពចំពោះមុខសាធារណៈជន ។

## ៨.១.គណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ

សមាជិកម្នាក់ៗត្រូវមានគណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំរបស់ខ្លួនតាមលំដាប់ថ្នាក់ និងអ្នកផ្តល់ធនធានថវិកា ។

**ឧទាហរណ៍ :** មេឃុំបានស្នើអោយស្មៀនឃុំ,សង្កាត់ យករបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅឱ្យអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ។

- សកម្មភាពដែលស្មៀនឃុំ,សង្កាត់យករបាយការណ៍នេះទៅឱ្យអង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្ត និងជាការបំពេញតួនាទី និងភារកិច្ចរបស់ស្មៀនឃុំ,សង្កាត់ ។

  នៅពេលត្រឡប់ដល់ឃុំវិញ ស្មៀនឃុំ/សង្កាត់បានរាយការណ៍ជូនមេឃុំ /សង្កាត់ថាគាត់បានប្រគល់របាយការណ៍រនេះទៅអោយលោក សុខ សុផល ជាមន្ត្រីរដ្ឋបាលនៃអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត នាព្រឹកថ្ងៃទី១៨ ខែមេសា ម្សិលមិញនេះ ព្រមទាំងបញ្ជាក់ផងដែរថា មន្ត្រីរូបនោះបានចុះហត្ថលេខាទៅលើ សៀវភៅបញ្ជូនលិខិត ។

ស្មៀនឃុំ សង្កាត់ យកសំបុត្រទៅឱ្យអង្គភាពរដ្ឋបាលមូលដ្ឋាន និងរាយការណ៍ជូនមេឃុំ ចៅសង្កាត់ មានន័យថា ស្មៀនមានគណនេយ្យភាពចំពោះមេឃុំ ចៅសង្កាត់ ។

## ៨.២.គណនេយ្យភាពចំពោះមុខសាធារណៈជន

មន្ត្រីសាធារណៈទាំងអស់ ត្រូវមានគណនេយ្យភាពចំពោះមុខសាធារណៈជន ពីព្រោះពួកគេត្រូវបានតែងតាំងឡើងដើម្បីបំរើសាធារណៈជន ។ កាលពីមុនជារឿយៗ គេសង្កេតឃើញថា មន្ត្រីរាជការត្រូវបានតែងតាំងឡើង ដើម្បីដឹកនាំប្រជាពលរដ្ឋ ។ ប៉ុន្តែបច្ចុប្បន្ននេះ តួនាទីរបស់មន្ត្រីរាជការ គឺផ្តោតទៅលើការផ្តល់សេវាជូនប្រជាពលរដ្ឋ ។ ដូច្នេះពួកគេត្រូវមានគណនេយ្យភាពចំពោះមុខប្រជាពលរដ្ឋទូទៅ ។ ដូចគ្នានេះដែរ ចំពោះភ្នាក់ងារឯកជនដែលផ្តល់សេវាកម្មដល់អតិថិជនរបស់ខ្លួន មិនត្រឹមតែមានគណនេយ្យភាពចំពោះអតិថិជនរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានគណនេយ្យភាពចំពោះ សាធារណៈជនទូទៅផងដែរ ។ ព្រោះថាការព្យាយាមផ្តល់ផលប្រយោជន៍ ឬតម្រូវចិត្តដល់អតិថិជន ក្រុមណាមួយ អាចធ្វើអោយមានផលប៉ះពាល់ដល់ក្រុមផ្សេងទៀត ឬសាធារណជនទូទៅ ។

**ឧទាហរណ៍ :** ក្រុមប្រឹក្សាឃុំ,សង្កាត់ សំរេចប្រើប្រាស់ថវិកាមូលនិធិឃុំ,សង្កាត់ ដើម្បីសាងសង់ផ្លូវលំមួយខ្សែប្រវែង ៣ គ.មក្នុងភូមិមួយ ។

. សកម្មភាពដែលក្រុមប្រឹក្សាឃុំ /សង្កាត់ ធ្វើសេចក្តីសំរេចអំពីការប្រើប្រាស់មូលនិធិឃុំ/សង្កាត់ និងអនុវត្តការសាងសង់ផ្លូវលំនេះ គឺជាការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ។

. បន្ទាប់ពីការសំរេច ក្រុមប្រឹក្សាឃុំ. សង្កាត់ ជំរាបជូនប្រជាពលរដ្ឋ :

- ដំណើរការ និងមូលហេតុនៃការធ្វើសេចក្តីសំរេចចិត្ត ក្នុងការសាងសង់ផ្លូវលំ

- ផ្តល់ចំលើយសមរម្យដល់អ្នកពាក់ព័ន្ធទាំងឡាយ ដែលទទួលផលប៉ះពាល់ពីការសាងសង់ផ្លូវលំមួយ ខ្សែនោះ

- លទ្ធផលនៃការសាងសង់ផ្លូវលំ ។

ក្រុមប្រឹក្សាឃុំ/សង្កាត់ សំរេចប្រើប្រាស់មូលនិធិឃុំ.សង្កាត់អនុវត្តការសាងសង់ផ្លូវលំ និងរាយការណ៍ជូនប្រជាពលរដ្ឋ មានន័យថា ក្រុមប្រឹក្សាឃុំ/សង្កាត់ មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋសាធារណជន ។

## ៩. ការឆ្លើយតប

ការឆ្លើយតបក្នុងន័យអភិបាលកិច្ចល្អមានន័យថា ជាការព្យាយាម ខិតខំប្រឹងប្រែងរបស់អង្គភាពស្ថាប័ន ដើម្បីបំរើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើង នៅក្នុងក្របខ័ណ្ឌ ពេលវេលាមួយដ៏សមហេតុផល ។

ការឆ្លើយតបអាចជា :

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ
- ដំណោះស្រាយដែលស្តែងឡើងជាសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាក់នានា
- ការឆ្លើយបំភ្លឺអំពីមូលហេតុដែលមិនអាចឈានដល់ការធ្វើសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬ ការលំបាកទាំងនោះ ព្រមទាំងជំរាបអំពីសំណើសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងបញ្ហា ឬការលំបាក់ទាំងនោះ ។

**ឧទាហរណ៍១ :** ប្រជាពលរដ្ឋម្នាក់បានមកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើតអោយកូនរបស់ខ្លួនដែលទើបនឹងកើត ។ ប្រជាពលរដ្ឋរូបនេះ បានមកដល់សាលាឃុំ ប៉ុន្តែគាត់មិនដឹងថាត្រូវជួបជាមួយអ្នកណាមួយនោះទេ ។ នៅពេលនោះមន្ត្រីឃុំម្នាក់បានស្វាគមន៍ និងសួរទៅកាន់ប្រជាពលរដ្ឋរូបនោះ ដើម្បីឱ្យដឹងថា តើគាត់ត្រូវការសេវាអ្វីខ្លះពីឃុំ ។ បន្ទាប់ពីដឹងច្បាស់ហើយ មន្ត្រីរូបនោះបានជំរាបដល់ប្រជាពលរដ្ឋនោះភ្លាម អំពីអ្នកដែលគាត់ត្រូវជួប ព្រមទាំងនាំទៅជួបមន្ត្រីនោះតែម្តង ។ មន្ត្រីឃុំដែលទទួល បន្ទុកបានបំពេញការងារជូនប្រជាពលរដ្ឋរូបនោះ ដោយទឹកចិត្តរីករាយ និងស្និទស្នាល ។ ទាំងនេះគឺជាទង្វើនៃ ការឆ្លើយតបរបស់ឃុំ ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**ឧទាហរណ៍២ :** នៅក្នុងភូមិ "ក" មានផ្ទុះជំងឺឆ្លងសត្វគោ ក្របី ។ មេភូមិបានធ្វើលិខិតមួយមកមេឃុំ ដើម្បីជួយធ្វើអន្តរាគមន៍ ។ នៅពេលទទួលបានលិខិតនេះភ្លាម មេឃុំបានកោះប្រជុំក្រុមប្រឹក្សាឃុំវិសាមញ្ញ ដើម្បីដោះស្រាយបញ្ហានេះ ។ បន្ទាប់ពីបានការសំរេចចិត្ត មេឃុំបានធ្វើសំណើទៅមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដើម្បីជួយធ្វើអន្តរាគមន៍ចុះចាក់វ៉ាក់សាំងដល់សត្វគោ ក្របី នៃភូមិជុំវិញភូមិ "ក" និង ព្យាបាលដល់ សត្វគោ ក្របី នៅក្នុងភូមិ "ក" ។ មេឃុំ ក៏បានជំរាបដល់ភូមិ "ក" ផងដែរអំពីលិខិត ស្នើសុំអន្តរាគមន៍ពី មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជាពត៌មាន ។

# ការបញ្ជ្រាបយេនឌ័រទៅក្នុងស្រទាប់នៃសង្គម

យុទ្ធសាស្ត្រនៃការបញ្ជ្រាបយេនឌ័រទៅក្នុងស្រទាប់នៃសង្គម គឺជាមធ្យោបាយ និងជាដំណោះស្រាយមួយដែលអាចប្រមូលបានថែមទៀតនូវធនធានសំរាប់ពង្រឹងនូវកិច្ចអភិវឌ្ឍន៍កម្ពុជា ។ អ្វី ដែលជាមោទនៈភាពថ្មីមួយទៀតសំរាប់ជាទុនដល់ការកសាង និងអភិវឌ្ឍន៍កម្ពុជានោះ គឺការប្រែប្រួលជាវិជ្ជមានខាងផ្នែកទស្សនៈ និងផ្នត់គំនិតរបស់សង្គម ចំពោះបញ្ហាស្ត្រី ។

គោលគំនិត និងនិន្នាការនៃការគាំទ្រស្ត្រីមិនមែនគ្រាន់តែសង្គមខ្មែរទេ គឺនៅលើសកលលោកតែម្តង ដែលបាន និងកំពុងយកចិត្តទុកដាក់ក្នុងការលើកកំពស់នូវតួនាទី និងការចូលរួមរបស់ស្ត្រីនៅក្នុងសង្គម ។

ហេតុអ្វីបានជាបញ្ហាស្ត្រីត្រូវបាននឹងកំពុងទទួលការយកចិត្តទុកដាក់ ? តើការបញ្ជ្រាបយេនឌ័រ មានផលប្រយោជន៍អ្វីខ្លះសំរាប់ទ្រទ្រង់ការអភិវឌ្ឍន៍នៅកម្ពុជា ?

ករណីជាក់ស្តែងសំរាប់កម្ពុជា គឺស្ត្រីមានចំនួនច្រើនជាងបុរស ។ កម្ពុជាជាប្រទេសដែលកំពុងទាមទារយ៉ាងទទូចអោយមានការអភិវឌ្ឍន៍ និងងើបចេញពីភាពក្រីក្រ ។ បច្ចុប្បន្ននេះប្រទេសកម្ពុជាជាប្រទេសក្រីក្រ ដូចនេះមានន័យថា ភាពក្រីក្រ កំពុងត្រូវបានគ្របដណ្តប់ទៅលើស្ត្រី ដែលមានចំនួនភាគច្រើននេះ ។

ដូចនេះចាំបាច់ត្រូវផ្តល់សិទ្ធិ និងឱកាសដ៏ពេញលេញដល់ស្ត្រីចូលរួមអភិវឌ្ឍន៍ និងដោះស្រាយបញ្ហារបស់ខ្លួន ។ នៅពេលដែលកម្ពុជាកំពុងធ្វើការអភិឌ្ឍន៍ មធ្យោបាយដ៏សំខាន់មួយ គឺត្រូវការចាំបាច់បំផុតនៅធនធានមនុស្សគ្រប់ផ្នែក និងគ្រប់ប្រភេទ បុរស-នារី) ។ ដូចនេះប្រាកដណាស់ថា ពុំមានការអភិវឌ្ឍន៍ណា មួយទទួលបានជោគជ័យ ដោយទុកធនធានស្ត្រីដែលមានចំនួនច្រើនជាងនៅក្នុងប្រទេសមួយមិនអោយចូលរួមនៅក្នុងការអភិវឌ្ឍន៍នោះទេ ។ កិច្ចការអ្វីក៏ដោយ ទាំងនៅក្នុងគ្រួសារ និងក្នុងកិច្ចការសង្គម កាលណាមានការចូលរួមទទួលខុសត្រូវអោយបានស្មើគ្នារវាងបុរសនិងស្ត្រីនៅក្នុងគ្រប់សកម្មភាពគ្រប់វិស័យ

នាំអោយកិច្ចការ នោះមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ ។

មានច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ មួយចំនួនទាំងក៏រិតជាតិ និងអន្តជាតិដែលបានចែងទាក់ទងទៅនឹងផលប្រយោជន៍របស់ស្ត្រី ។ ពោលគឺដំណើរការប្រព្រឹត្តទៅ នៃជីវភាពជាប្រចាំរបស់ស្ត្រី ត្រូវបានការពារ និងហ៊ុំព័ទ្ធដោយច្បាប់ និងលិខិតបទដ្ឋាននានា ជាច្រើនទៀត ។

ដូចនេះភារកិច្ច និងបេសកម្មចំបងរបស់ស្ត្រី គឺការប្តេជ្ញាចិត្តរបស់ស្ត្រីខ្លួនឯង រួមជាមួយនឹងសេចក្តីព្យាយាមទាំងឡាយដើម្បីពង្រឹង និងបំពេញបន្ថែមនូវសេចក្តីត្រូវការផ្នែកសមត្ថភាព និងការខ្វះខាតមួយចំនួន ទៀត ដែលស្ត្រីមាន ។ ធ្វើដូចនេះបាន ទើបសង្គមនឹងកាន់តែមានជំនឿលើស្ត្រី របស់យើង ។

## ក. ច្បាប់ រដ្ឋធម្មនុញ្ញ :

✧ **មាត្រា៣៥ :** ចំនុចទី១ ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួម យ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ " ។

✧ **មាត្រា៣៦ :** ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម " ។
ប្រជាជនខ្មែរទាំងពីរភេទ មានសិទ្ធទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។
ការងារមេផ្ទះមានតំលៃស្មើគ្នា និងកំរៃ ដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ " ។

✧ **<u>មាត្រា៤៥ :</u>** ចែងថា "ការរើសអើងគ្រប់ប្រភេទប្រឆាំងស្ត្រីភេទ ត្រូវបានលុបបំបាត់ចោល"
- ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។
- បុរស និងស្ត្រីមានសិទ្ធិស្មើគ្នា ក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ " ។

✧ **<u>មាត្រា៤៦ :</u>** ចែងថា "អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។
- ត្រូវហាមឃាត់មិនអោយ មានការបញ្ឈប់ នារីពីការងារ ដោយមូលហេតុមានគត៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីត ភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗ ទៀត ។
- រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈអោយនារី ពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរមានលទ្ធភាពព្យាបាលជំងឺអោយកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ " ។

## ខ. អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ :

- ✧ **មាត្រា១៩ :** ចែងថា "ក្រុមប្រឹក្សាឃុំ,សង្កាត់ ត្រូវតែងតាំងសមាជិក ក្រុមប្រឹក្សាឃុំ /សង្កាត់ម្នាក់ជានារី អោយទទួលបន្ទុកកិច្ចការនារី និងកុមារ " ។
- ✧ **មាត្រា២២ :** ចំនុច៤ចែងថា "យោងតាមសភាពការជាក់ស្តែងនៃភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ /សង្កាត់ត្រូវខិតខំជ្រើសរើសនារីអោយទទួលតំណែងជាមេភូមិ ឬអនុប្រធានភូមិ "។

## គ. ច្បាប់ សិទ្ធិមនុស្ស-សិទ្ធិស្ត្រី :

- មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា គឺចំពោះកិច្ចការស្មើគ្នាត្រូវអោយទទួលកម្រៃស្មើគ្នា)

- សិទ្ធិមានសមភាពខាងផ្លូវភេទ គឺភេទណាក៏ដូចភេទណាអាចធ្វើអ្វីៗបានតាមសមត្ថភាព និងលទ្ធភាព )

- សិទ្ធិមានសមភាពរវាងប្តី-ប្រពន្ធ គឺភាពជាប្រពន្ធមានតំលៃស្មើគ្នា នឹងប្តីក្នុងរង្វង់គ្រួសារ)

- សិទ្ធិទទួលការការពារពីការកេងប្រវ័ញ្ច ១គឺសង្គម និងរដ្ឋមានកាតព្វកិច្ចការពារកុំអោយមានការកេងប្រវ័ញ្ចលើស្ត្រីភេទ តាមគ្រប់មធ្យោបាយ)

- សិទ្ធិទទួលការឈប់សំរាកពេលសំរាលកូន គឺត្រូវមានច្បាប់អនុញ្ញាតិឱ្យស្ត្រីឈប់សំរាកពីការងារក្នុងពេលមុនពេល និងក្រោយពេលសំរាលកូន)

- សិទ្ធិរួចទោសប្រហារជីវិតក្នុងពេលមានគភ៌ ប្រសិនបើមានទោសប្រហាជីវិត ) ទោះនោះមិនត្រូវអនុវត្តលើស្ត្រីមានផ្ទៃពោះឡើយ កម្ពុជាគ្មានទោសប្រហារជីវិតទេ) ។

តាមរយៈការលើកឡើងខាងលើនេះបានបង្ហាញអោយឃើញថា ក្រៅពីច្បាប់នានា ដែលបានការពារសិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋទូទៅ នៅមានច្បាប់មួយចំនួនទៀត ដែលបានចែងជាពិសេស ដើម្បីផ្តល់នូវសិទ្ធិ ក៏ដូចជាដើម្បីការពារនូវប្រយោជន៍ដោយឡែកផ្សេងទៀតសំរាប់ស្ត្រី ។

ដូចនេះការបែងចែក ការកំណត់ ឬកំរិតការចូលរួមរបស់ស្ត្រីនៅក្នុងសង្គម គឺជាការរើសអើង ហើយសកម្មភាពនៃការរើសអើងនេះ វាជាស`ម្មភាពផ្ទុយនឹងច្បាប់ ។

## គោលបំណងនៃការសិក្សាយេនឌ័រ

១. ដើម្បីជួយពង្រឹងការយល់ដឹងពី តម្លៃ និងអត្តសញ្ញាណរបស់ខ្លួន

២. ដើម្បីបណ្តុះភាពយល់ដឹង នូវរបៀបកំណត់តួនាទីរបស់បុរស និងស្ត្រីក្នុងសង្គម ដោយស្គាល់ពីអ្វីអាច មានការផ្លាស់ប្តូរ និងប្រែប្រួល

៣. ដើម្បីបង្កើតអោយមានសមភាព ក្នុងការចោទសួរ និងភាពស្ទាត់ជំនាញក្នុងការគិតគូរ

## ១. និយមន័យ អំពីភេទ និងយេនឌ័រ :

ដូចយើងបានដឹងរួចមកហើយ ក្នុងជីវិតសព្វថ្ងៃ ស្ត្រីនិងបុរសត្រូវបានរស់នៅ និងធ្វើការជាមួយគ្នាយ៉ាង ជិតស្និទ្ធក្នុងការទំនាក់ទំនងដែលពឹងផ្អែកគ្នាទៅវិញទៅមក ។ ប៉ុន្តែក្នុងពេលជាមួយគ្នានេះដែរ គេមានលក្ខណៈប្លែកគ្នាជាច្រើន ដូចជា រូបរាងកាយ អត្តចរិក របៀបទាក់ទង រឺក៏តួនាទីក្នុងសង្គម ។

តាំងពីដើមមកមនុស្សសឹងតែទាំងអស់យល់ថា លក្ខណៈខុសគ្នារវាងស្ត្រី និងបុរស គឺជារឿង " ភេទ " ដែលធម្មជាតិកំណត់មកតាមរយៈជីវសាស្ត្រខុសគ្នា ។ ហើយដោយសារភេទខុសគ្នា ស្ត្រី និងបុរសត្រូវមានតួនាទី និងភារកិច្ចខុសគ្នាដែរ ។

ក្រោយមក លទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រជាច្រើនបានបង្ហាញអោយឃើញថា ភេទ និងការធ្វើ អោយស្ត្រីមានគតិ គឺជារឿងដែលមនុស្សអាចច្នៃបាន ដោយមិនចាំបាច់ទទួលការកំណត់ទាំងស្រុងនោះទេ ។ ដូចនេះតួនាទី និងភារកិច្ចរបស់ស្ត្រី និងបុរស ក៏មនុស្សអាចរៀបចំអោយមានលក្ខណៈដូចគ្នា និងអាចប្តូរគ្នាទៅ វិញទៅមកបានដែរ ។

ដើម្បីបញ្ជាក់អោយឃើញច្បាស់អំពីលក្ខណៈជីវសាស្ត្រ និងលក្ខណៈសង្គមសាស្ត្ររបស់ស្ត្រី និងបុរស យើងប្រើ ពាក្យពីរគឺ : **<u>ភេទ និង យេនឌ័រ</u>**

| ***អ្វីជាភេទ ?*** | ***អ្វីជាយេនឌ័រ ?*** |
|---|---|
| **ភេទ** សំដៅទៅលើលក្ខណៈជីវសាស្ត្រ ដែលទាក់ទងទៅនឹងរូបរាងរបស់ស្ត្រី និងបុរស<br>**ភេទ** កំណត់នូវលក្ខណៈអចិន្ត្រៃយ៍ និងស្ថិតស្ថេរ ដែលមិនអាចផ្លាស់ប្តូរបានរវាងបុរស និង ស្ត្រី<br><br>***<u>ឧទាហរណ៍ :</u>***<br>- ស្ត្រីអាចពរពោះអាចសំរាលកូនបាន និងបំបៅកូនបាន បុរសមិនអាចពរពោះ សំរាលកូន និងបំបៅកូនបានដូចស្ត្រីទេ ។ | **យេនឌ័រ** សំដៅលើលក្ខណៈ និងទំនាក់ទំនងរវាងស្ត្រី និងបុរសក្នុងសង្គម<br>**យេនឌ័រ** កំណត់លក្ខណៈ និងអាស្រ័យលើលក្ខខណ្ឌរស់នៅ ការអប់រំ និងរបបសង្គម<br><br>***<u>ឧទាហរណ៍ :</u>***<br>- ស្ត្រីធ្វើជានាយកដ្ឋានមន្ត្រីមិនមែនមានតែបុរសទេ)<br>- បុរសអាចធ្វើកិច្ចការផ្ទះ និងមើលកូន មិនមែនតែស្ត្រីទេ) ។ |

លក្ខណៈយេនឌ័ររបស់ស្ត្រី និងបុរសផ្លាស់ប្តូរទៅតាមពេលវេលា និងប្រែប្រួលទៅតាមសង្គមខុសគ្នា តាមរយៈការអប់រំ ជួនកាលការខ្មាស់អៀន និងការពុំសូវមានជំនឿលើខ្លួនឯង លើខ្លួនយុវតីអាចជំនះបាន ។ តាមសង្គម ខុសគ្នា បុរសទីក្រុងចូលចិត្តរៀបការក្នុងវ័យចំណាស់ ហើយមានកូនតិចជាងបុរសនៅជនបទ ។ ស្ថានភាពស្ត្រីសព្វថ្ងៃនេះ មានការផ្លាស់ប្តូរទៅមុខ លើវិស័យជាច្រើន : តួនាទីស្ត្រីត្រូវបានប្រសើរឡើង ដោយសារការគាំទ្រច្បាប់រដ្ឋធម្មនុញ្ញថ្មី ច្បាប់ជឿនលឿនមួយចំនួន និងការអប់រំ ។ សព្វថ្ងៃស្ត្រីមួយចំនួន បានទទួលនូវប្រាក់កំរៃ ការងារគ្រាន់បើជាងពីមុន គេបានរៀនសូត្រជាងមុន ហើយចូលរួមបានច្រើនក្នុង ចលាចលមហាជន ។ ក្នុងគ្រួសារ ខ្លះបុរសជួយចែករំលែកកិច្ចការផ្ទះ មើលកូន និងថែរក្សាឪពុក-ម្តាយ ។ ទោះបីយ៉ាងណាក៏ដោយ វិសមភាពរបស់យេនឌ័រ នៅតែមានច្រើននៅឡើយ ជាអាទិ៍ស្ត្រី នៅតែទទួលប្រាក់កំរៃ តិចជាង បុរសចំពោះការងារដូចគ្នា នៅតែទទួលបន្ទុកលើការងារផ្ទះដដែល សមត្ថភាពស្ត្រីនូវតែមានមន្ទិល ស្ត្រី និង យុវតីជាច្រើនកំពង់តែប្រឈមមុខនឹងបញ្ហាហិង្សា និងការចាប់រំលោភ ។

កត្តាសេដ្ឋកិច្ច វប្បធម៌ និងការអប់រំ សុទ្ធសឹងតែមានឥទ្ធិពលលើការងារយេនឌ័រ ។ ប្រសិនបើ យើងស្គាល់នូវមូលហេតុ ដែលនាំអោយមានវិសមភាពយេនឌ័រ នោះយើងអាចរកឃើញនូវវិធានការចាំបាច់ ដើម្បីធ្វើការផ្លាស់ប្តូរស្ថានភាពនោះបាន ជាពិសេសការចាំបាច់ និងផលប្រយោជន៍នៃការងារប្រចាំថៃរបស់ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាចធ្វើអោយប្រសើរឡើងនូវលក្ខខ័ណ្ឌសេដ្ឋកិច្ច វប្បធម៌ និងការអប់រំ ដែលនឹង លើកស្ទួយស្ថានភាពសង្គម និងសហគមន៍ព្រមទាំងស្ត្រីផង ។

✓ **ចូរចងចាំ :** យេនឌ័រមានលក្ខណៈខ្លាំងក្លា ហើយអាចប្រសើរឡើងតាមរយៈ

- ដំណើរការសង្គមភាវូបណីកម្ម គ្រួសារ សាលារៀន និងសង្គម )
- ផ្លាស់ប្តូរនូវកត្តារចនាសម្ព័ន្ធសេដ្ឋកិច្ចនយោបាយ និងវប្បធម៌ ការផ្លាស់ប្តូរនូវភាពអយុត្តិធម៌ក្នុងសង្គម និងផ្នត់គំនិត និងទំនៀមទំលាប់ចាស់គំរិល ។
- ផ្លាស់ប្តូរច្បាប់នយោបាយក្នុងកំរិតថ្នាក់ជាតិ និងអន្តរជាតិ ។

## ២. តួនាទី យេនឌ័រ និងតំរូវការយេនឌ័រ

ដើម្បីយល់ពីទំនាក់ទំនងយេនឌ័រក្នុងជីវភាពប្រចាំថ្ងៃ យើងគួរតែស្គាល់ពីតួនាទីខុសគ្នា និងតំរូវការ ខុសគ្នារវាងស្ត្រី និងបុរស ។

**ក. តួនាទី យេនឌ័រ :** ស្ត្រីនិងបុរសប្រកបរបរខុសគ្នាក្នុងការបង្កបង្កើនផលក្នុងគ្រួសារ និងក្នុង សហគមន៍ ។ យើងចែកតួនាទីយេនឌ័រជាបីប្រភេទគឺ តួនាទីបានប្រាក់កំរៃ តួនាទីឥតបានប្រាក់កំរៃ និង តួនាទីក្នុង សហគមន៍ ។

- **តួនាទីបានប្រាក់កំរៃ** : គឺជាការងាររកស៊ីចិញ្ចឹមជីវិត ការងារផលិតម្ហូបចំណីរបស់របរ ឬ ការងាររកប្រាក់ចំណេញ ។ មានស្ត្រី និងបុរស ធ្វើកិច្ចការនេះ ។ ក្នុងការករណីជាច្រើនការងារនេះច្រើនតែ ធ្លាក់ទៅលើបុរសដូចជាភ្ជួររាស់ ជួសជុលម៉ាស៊ីន រីឯស្ត្រីច្រើនតែដកស្ទូង ជំរះស្មៅ ត្បាញរវៃ ។ ការងារស្ត្រី ច្រើន ទទួលប្រាក់កំរៃទាបជាការងារក្រៅផ្លូវការ ដែលនៅទីនោះបុរសជាច្រើនតែងទទួលយក ការងារបច្ចេកទេស និងទទួលប្រាក់កំរៃច្រើន ។ ទាំងនេះបានធ្វើអោយយល់ថា បុរសមានតួនាទីសំខាន់ ក្នុងការរកប្រាក់កំរៃបាន ច្រើន ហើយជាអ្នកមានអំណាចក្នុងគ្រួសារ ។ តាមពិតស្ត្រីក៏មានតួនាទីសំខាន់ នៅក្នុងគ្រួសារដូចបុរសដែរ គឺ អ្នករកប្រាក់កំរៃបានដែរ ជាក់ស្តែងសព្វថ្ងៃមានស្ត្រីប្រមាណ ៨០% ជា កម្មកររោងចក្រ ។

- **តួនាទីឥតបានប្រាក់កំរៃ** : គឺជាការងារដែលចាំបាច់ក្នុងការទ្រទ្រង់គ្រួសារ ដូចជាការថែរក្សា កូន ដាំស្ល បោកគក់ និងថែរក្សាតំលៃគ្រួសារ ។ ការងារនេះភាគច្រើនស្ត្រីជាអ្នកធ្វើ ហើយត្រូវការពេល វេលានិងបញ្ចេញថាមពលច្រើន ប៉ុន្តែរហូតដល់ពេលនេះត្រូវគេចាត់ថា មិនបានទទួល ប្រាក់កំរៃខ្ពស់ទេ ។ ពេលវេលា និងថាមពលសរុបដែលស្ត្រី ចំណាយទៅលើការងារទាំងនេះគឺជាឧបសគ្គមួយ ក្នុងចំណោម ឧបសគ្គ ដទៃដែលឃាយាំងឱកាសស្ត្រីក្នុងការចូលរួមជាមួយមហាជនក៏ដូចជាការលើកកំពស់សមត្ថភាពរបស់ ខ្លួន ។

- **តួនាទីក្នុងសហគមន៍**

**. ការចូលរួមក្នុងសកម្មភាពទូទៅសំរាប់ភាព ប្រសើរឡើង នៃលក្ខខ័ណ្ឌរស់នៅរបស់សហគមន៍ :**

ស្ត្រីភាគច្រើនស្ម័គ្រចិត្តចូលរួមក្នុងសកម្មភាពនានាដែលជាផលប្រយោជន៍គ្រួសារ និងសហគមន៍ ដូចជាផែនការក្នុងគ្រួសារ និងការថែរក្សាធនធានសម្ភារភាព អនាម័យទឹកស្អាត ការថែរក្សា សុខភាពបឋម និងការអប់រំសុខភាពសហគមន៍ ) ។

**. ការចូលរួមក្នុងការ ចាត់ចែងសហគមន៍**

នេះជាការចូលរួមក្នុងកិច្ចការ សាធារណៈជាផ្លូវការតាមរយៈការចូលរួមជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ រឺ ជួនកាលមិនមែនជាផ្លូវការតាមរយៈការចូលរួមបុណ្យទាន ពិធីជប់លេជប់លៀងផ្សេងៗ សកម្មភាពទាំងនេះច្រើនតែបានទៅលើបុរសក្នុងតួនាទីជាអ្នកដឹកនាំ ។

ប្រពៃណីសង្គមបានកំណត់ នូវករណីយ៍កិច្ចទទួលខុសត្រូវ និងសកម្មភាពខុសៗគ្នារវាងស្ត្រី និងបុរស ទៅតាមតួនាទីយេនឌ័រ ដែលមានក្នុងសង្គម ។ នេះហៅថា ការបែងចែកយេនឌ័រ តាមរយៈការងារ ។ ការ បែងចែកយេនឌ័រតាមការងារ កំនត់នូវសកម្មភាពស្ត្រី និងបុរសលើមូលដ្ឋានសមត្ថភាព ការបែងចែក យេនឌ័រ តាមការងារពុំមែនគ្រាន់តែធ្វើសកម្មភាពដោយឡែកៗប៉ុណ្ណោះទេ ក៏ប៉ុន្តែវាចងភ្ជាប់ពីសកម្មភាព មួយទៀត ទៅវិញទៅមក ។

**ឧទាហរណ៍ :** ជាទូទៅការងារដែលប្រើប្រាជ្ញាច្រើន តែងមានកំរៃខ្ពស់ជាងការងារធ្វើដោយ កំលាំង ។ កាលពីមុនមនុស្សប្រុសអាចមានអត្តិភាពទទួលយកការងារខាងប្រាជ្ញា ចំណែកស្ត្រីច្រើនធ្វើការងារខាងកំលាំង ។ ការងារដែលស្ត្រីធ្វើជាប្រភេទការងារ "ធម្មជាតិ" ដូចជាថែរក្សាកូន រីឯការងារបុរសជាប្រភេទការងារសង្គម វិរប្បធម៌ ដូចជាការងារចាត់ចែងគ្រប់គ្រង ត្រួតពិនិត្យដឹកនាំគ្រួសារ និងសហគមន៍។ ដូចនេះហើយការងារស្ត្រីច្រើនតែមានតំលៃតិចជាងការងារបុរស ។

យើងអាចឃើញជាក់ស្តែងក្នុងជីវិតសព្វថ្ងៃថា ជាការបែងចែកយេនឌ័រក្នុងការងារ មានការប្រែប្រួលម្ត...តម្តងៗ ទៅតាមពេលវេលា ក៏ប៉ុន្តែការប្រែប្រួលនេះមានភាពយឺតណាស់ ។ ខាងក្រោមនេះ គឺជាការបែងចែកការងារស្ត្រី និង បុរស :

| សកម្មភាព | បុរស | ស្ត្រី |
|---|---|---|
| ១. ការងារទទួលប្រាក់កំរៃ | ៩ម៉ោង | ៩ម៉ោង |
| ២. ការងារបានប្រាក់កំរៃតិចរឺឥតកំរៃ | ២ម៉ោង | ៧ម៉ោង |
| ៣. ពេលវេលាទំនេរដើរកំសាន្ត | ៥ម៉ោង | ១ម៉ោង |
| ៤. ទទួលទានដំណេក | ៨ម៉ោង | ៧ម៉ោង |

ឌីយ៉ាក្រាមនេះបញ្ជាក់ថា ស្ត្រីទទួលបន្ទុកកិច្ចការផ្ទះធ្ងន់ធ្ងរជាងបុរស ។ តារាងខាងលើ បញ្ជាក់ឱ្យឃើញថា បុរសមានពេលទំនេរសំរាកច្រើនជាងស្ត្រីចំនួន ៥ម៉ោង ។ នេះជាការចាំបាច់ណាស់ក្នុងការរាប់នូវតួនាទី និងការងាររវាងស្ត្រី និង បុរស :

- ធ្វើឱ្យមតិសាធារណៈកាន់តែយល់ដឹងខ្លាំងឡើង និងវាយតំលៃយ៉ាងច្បាស់ នូវរាល់ការងារទាំងអស់ ដែលបានធ្វើក្នុងរង្វង់គ្រួសារព្រមទាំងសហគមន៍ផង ។
- ត្រូវចេះស្វែងរកកត្តាដែលគាំទ្រស្ត្រី ដើម្បីឱ្យមានការកាត់បន្ថយនូវបន្ទុកដ៏ធ្ងន់ធ្ងររបស់ស្ត្រីក្នុងរង្វង់គ្រួសារ ។

**ខ- តំរូវការ យេនឌ័រ :**

រាល់កម្មវិធីទាំងអស់ សុទ្ធតែមានបំណងល្អក្នុងការជួយប្រជាជនអោយមានស្ថានភាពកាន់តែល្អឡើង យើងក៏គួរតែបែងចែកឱ្យច្បាស់រវាងតំរូវការស្ត្រី-បុរស ។ តំរូវការទាំងនេះ ធ្វើឱ្យយើងមើលឃើញនូវសកម្មភាពខុសគ្នានៃកម្មវិធីទាំងនោះ ។

**តំរូវការជាក់ស្តែង :**

ការឆ្លើយតបយ៉ាងឆាប់ និងចាំបាច់ដោយផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ ។ ប្រជាជនទាំងអស់តែង តែបែងចែក និងចែករំលែកទៅវិញទៅមកនូវការលំបាកក្នុងការរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់គេ ។

**ឧទាហរណ៍ :** ដូចជាបញ្ហាម្ហូបចំណី ទឹក និង បញ្ហាសុខភាព ។ ប៉ុន្តែគេនឹងមានតំរូវការជាក់ស្តែងខុសគ្នាទៅតាមស្ត្រី រឺបុរសក្នុងករណីនេះ ដោយសារតែមានតួនាទីយេនឌ័រខុស១ គ្នា លើការទទួលខុសត្រូវនឹងបន្ទុកចំពោះគ្រួសារ ។ ស្ត្រីអាចនឹងមានតំរូវការជាអាទិភាពទៅលើប្រាក់ចំណូលគ្រួសារទៅលើការបង្កើនប្រាក់ចំណូល ទឹកស្អាតការថែរក្សាសុខភាពសំរាប់មនុស្សចាស់ រឺផ្តល់ការអប់រំចំពោះកុមារ ។

ចំណែកឯបុរស ប្រហែលជាបារម្ភច្រើនទៅលើបញ្ហាផ្សេង១ ដូចជាបញ្ហាដីធ្លី បញ្ហាប្រព័ន្ធទឹក បច្ចេកទេស រឺជំនាញអភិវឌ្ឍន៍ទៅវិញ ។

តំរូវការជាក់ស្តែងរបស់ស្ត្រីមានភាពច្បាស់លាស់ និងចំពោះមុខភ្លាម១ ដែលទាក់ទងទៅនឹងតំរូវការគ្រួសារ និងកុមារ ។ តំរូវការជាក់ស្តែង របស់បុរសច្រើនតែទាក់ទងទៅនឹងការងារបង្កបង្កើនផល ។ ក្នុងការបំពេញការងារជាក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវស្គាល់ឱ្យបាននូវតំរូវការទាំងពីរនេះ ដើម្បីធ្វើអោយមានភាពល្អ ប្រសើរឡើងនូវលក្ខខ័ណ្ឌរស់នៅ ហើយនឹងធ្វើការផ្លាស់ប្តូរនូវទំនៀមទំលាប់មិនស្មើគ្នានៃការបែងចែកការងារ រវាងបុរស និងស្ត្រី ។ ហេតុនេះហើយយើងក៏ត្រូវតែមាននូវតំរូវការជាយុទ្ធសាស្ត្រ ទាំងនោះដែរ ។

***តំរូវ ការជាយុទ្ធសាស្ត្រ***

គឺជាតំរូវការដែលទាក់ទងទៅ នឹងសមត្ថភាពសង្គមរវាងបុរស និងស្ត្រី ។ ការស្គាល់នូវតំរូវការទាំងនេះអាចជួយផ្តល់ចំណាចដល់ស្ត្រីអោយមានឱកាសកាន់តែច្រើនក្នុងការអប់រំក្នុងការទទួលបៀវត្សស្មើគ្នា និងការចូលរួមស្មើគ្នាជាមួយបុរសក្នុងការធ្វើសេចក្តីសំរេច ។

**ឧទាហរណ៍ :** ការកាត់បន្ថយនូវភាពហិង្សា និងការរំលោភផ្លូវភេទ ការបែងចែកការងារស្មើគ្នាក្នុងការបង្កបង្កើនផល ការផ្តល់អំណាច និងការចូលរួមក្នុងនយោបាយ ព្រមទាំងកិច្ចការសង្គមផ្សេង១ ទៀត ។

## ៣. ការចូលរួម និងការទទួលបានការប្រើប្រាស់ គ្រប់គ្រងលើធនធាន ៖

ការបង្កបង្កើនផលការងារបន្ទាប់បន្សំ និងការងារសហគមន៍ សុទ្ធតែត្រូវអោយប្រើប្រាស់នូវធនធាន ដូចជា ដីធ្លី ឥណទាន ពត៌មាន ការហ្វឹកហ្វឺន និងពេលវេលា ។ តាមរយៈធនធានទាំងនេះ ប្រជាពលរដ្ឋអាច នឹងទទួលបាននូវផលប្រយោជន៍សំរាប់សហគមន៍ និងគ្រួសាររបស់គេ ។ ក្នុងការធ្វើផែនការ រឺការអនុវត្តន៍ កម្មវិធី យើងគួរតែផ្តល់ឱកាសអោយបានច្រើនដល់ស្ត្រី ដើម្បីអោយគេមានធនធានទាំងនេះព្រមទាំងលើក ទឹកចិត្ត អោយគេចូលរួមក្នុងសកម្មភាពទាំងនេះ ។ ជាពិសេសយើងគួរតែយកចិត្តទុកដាក់ទៅ លើវិសមធម៌ រវាងបុរស និងស្ត្រី ក្នុងការធ្វើ និងត្រួតពិនិត្យលើធនធានដូចជា ក្នុងស្ថានភាពជនបទជាច្រើន ស្ត្រីអាចទទួល នូវចំណែកដីធ្លី ក៏ប៉ុន្តែគាត់ពុំបានត្រួតពិនិត្យលើការប្រើប្រាស់ដីធ្លី ក្នុងនាមខ្លួនឯង ហើយកម្មសិទ្ធិកាន់កាប់ លើដីនោះ ពុំមានដាក់ឈ្មោះខ្លួនជាស្ត្រីភេទនោះទេ ។ មានករណីច្រើនណាស់ដែលសិទ្ធិស្ត្រីត្រូវបានគេរំលោភ ពិសេសពី កម្មសិទ្ធិ កាន់កាប់ទ្រព្យសម្បត្តិក្នុងគ្រួសារ រឺខ្ចីប្រាក់ឥណទានជាដើម ។

## ៤. ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីផ្សេងៗ ៖

ក្រោយពីបានកំណត់ និងយល់នូវគំនិតដែលបានរៀបរាប់ខាងលើនេះ យេនឌ័រតួនាទីយេនឌ័រ តំរូវ ការជាក់ស្តែង និងតំរូវការជាយុទ្ធសាស្ត្រ និង ការត្រួតពិនិត្យលើធនធាន› ជំហានបន្ទាប់គឺត្រូវយកចំណេះ ដឹងទាំងនេះ បញ្ចូលទៅក្នុងកម្មវិធីច្បាស់លាស់ណាមួយ រឺ គំរោងណាមួយដើម្បីបំពេញអោយល្អនូវអ្វីដែល ជាសេចក្តីត្រូវការពិតប្រាកដ សំរាប់បុរស និង ស្ត្រី ។យើងហៅថា ការអនុវត្តន៍នេះ ជាកម្មវិធីវិភាគយេនឌ័រ ។

## អ្វីជាវិភាគយេនឌ័រ

*វិភាគយេនឌ័រ គឺជាវិធីមួយកំណត់នូវស្ថានភាព និង ប្រមូលផ្តុំនូវពត៌មានចាំបាច់សំរាប់ផែនការអនុវត្ត និង ពិនិត្យតាមដានពីគំរោងកម្មវិធីមួយ ដែលមាន សមធម៌ ចំពោះស្ត្រី និង បុរស ។*

គោលបំណងចំបងរបស់វិភាគយេនឌ័រ ប៉ាន់ស្មានតំរូវការយេនឌ័របែបណា ដែលបានឆ្លុះបញ្ចាំងក្នុងកម្មវិធី រឺ គំរោងណាមួយ រឺ សំណូមពរដែលអាចវាស់ស្ទង់នូវកំរិតលើកទឹកចិត្តអោយកាន់តែមានសកម្មភាព ចូលរួមខ្លាំងក្លាឡើងថែមទៀត ព្រមទាំងផលប្រយោជន៍ដែលទទួលបានពីសកម្មភាពទាំងនោះ ។

## ដំណាក់កាល នៃការវិភាគយេនឌ័រ :

នៅពេលពិនិត្យកម្មវិធី រឺគំរោងណាមួយអ្នកគួរតែលើកឡើងនូវសំណួរដូចខាងក្រោម :

- អ្វីជាតួនាទីរបស់ស្ត្រី និងតួនាទីរបស់បុរស តួនាទីយេនឌ័រ ) ?
- តើអ្វីតំរូវការជាក់ស្តែងរបស់ស្ត្រី ? និងអ្វីជាតំរូវការជាក់ស្តែងរបស់បុរស ?
- តើអ្វីជាយុទ្ធវិធីនៃតំរូវការរបស់ស្ត្រី ? តើកម្មវិធី រឺគំរោងការណ៍បានលើកឡើងនូវតំរូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី ដោយរបៀបណា ?
- តើនរណាជាអ្នកធ្វើ និងជាអ្នកត្រួតពិនិត្យលើធនធានកម្មវិធី/គំរោង ថវិកាវគ្គបណ្តុះបណ្តាលពត៌មាន ) ?
- អ្នកណាជាអ្នកធ្វើសេចក្តីសំរេចលើធនធានគំរោងទាំងនោះ ? តើមានឱកាសក្នុងការបង្កើននូវតួនាទី ក្នុងការធ្វើសេចក្តីសំរេចរបស់ស្ត្រីដែររឺទេ ?
- តើអ្វីជាមូលហេតុសំខាន់នៃវិសមភាពយេនឌ័រក្នុងសហគមន៍ និង សគ្រួសារ វប្បធម៌ សេដ្ឋកិច្ច ការអប់រំ ) ?
- អ្វីទៅដែលត្រូវធ្វើដើម្បីជំរុញសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី ?

# ចូរចងចាំក្នុងពេលធ្វើវិភាគយេនឌ័រ

- ជំរុញទាំងបុរស និងស្ត្រីក្នុងការស្វែងរកពត៌មានឱ្យបានគ្រប់គ្រាន់សំរាប់តួនាទីនិងលក្ខខណ្ឌ
- ពិភាក្សាប្តូយោបល់ និងធ្វើការងារជាមួយអង្គការស្ត្រី និងស្ត្រីដឹកនាំក្នុងសហគមន៍
- ត្រូវមានកិច្ចសហការណ៍ និងគាំទ្រពីបុរស ។ ព្យាយាមរកឱកាស និងនិយាយជាមួយ បុរសដើម្បីបង្កើតការយល់ដឹង ។
- ជំរុញពេញទំហឹងនូវកម្មវិធី វីគំរោង សកម្មភាពស្ត្រី និងជាពិសេសក្នុងការ ធ្វើសេចក្តីសំរេច ។
- ចល័ត និងធ្វើការជាមួយនឹងស្ថាប័នមូលដ្ឋាន ។
- រៀបចំអោយបានទៀងទាត់នូវវេទិកាពិភាក្សា និងចែករំលែកបទពិសោធន៍ អំពីយេនឌ័រ ជាពិសេសអំពីលទ្ធផលកម្មវិធី វីគំរោងនានា ។

និយាយរួមការស្គាល់នូវតំរូវការយេនឌ័រ និងការធ្វើអោយប្រសើរឡើងនូវតួនាទីរបស់ស្ត្រី គឺជាការងារ យូរអង្វែង ដែលតម្រូវអោយមានការផ្លាស់ប្តូរនូវអាកប្បកិរិយា និងអត្តចរិតរបស់ស្ត្រី និងបុរស ។ ក្នុងខណៈ នៃការផ្លាស់ប្តូរត្រូវការពេលវេលាមួយចំនួនធ្វើការរួមគ្នា ដើម្បីដោះស្រាយនូវបញ្ហាវិសមភាពរបស់ស្ត្រី ។ ក្នុងតួនាទីជាអ្នកដឹកនាំ ឃុំ-សង្កាត់ អ្នកនឹងមានឱកាសក្នុងការបញ្ចូលយេនឌ័រទៅក្នុងកម្មវិធីវីគំរោងអភិវឌ្ឍន៍ និងធ្វើការយល់ដឹងលើយេនឌ័រ ក្នុងបណ្តាប្រជាពលរដ្ឋ និងសង្គមកាន់តែប្រសើរឡើង ។

## ៥. យុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រ

**៥.១.គោលដៅ** : ពង្រឹងការតស៊ូមតិ និងការបញ្ចុះបញ្ចូលសំរបសំរួលជាមួយរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងនយោបាយកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អ តាមរយៈគោលដៅនេះ យើងរំពឹងទុកថាអាចនឹងបង្កើនភាពអង់អាចនឹងជំរុញការចូលរួមយ៉ាងសមធម៌ និងសមភាពរបស់ស្ត្រីគ្រប់កំរិតនៃកិច្ចអភិវឌ្ឍន៍ ។ យុទ្ធសាស្ត្រ ខាងលើនេះ មានសមាសភាគសំខាន់១ ដូចខាងក្រោម :

ក/ ការបង្កើនការប្តេជ្ញាចិត្ត និងសមត្ថភាពរបស់ស្ត្រី

ខ/ ការជំរុញ និងការតស៊ូមតិអោយមានគោលការណ៍ជាតិមួយឆ្លើយតបទៅ នឹងការបញ្ជ្រាបយេនឌ័រ

ច/ ការជំរុញ និងគាំទ្រការចូលរួមរបស់ស្ត្រីនៅក្នុងការកសាងផែនការអភិវឌ្ឍន៍ និងអភិបាលកិច្ច នៅគ្រប់កំរិត

ឃ/ គាំទ្រ និងជំរុញអោយមានសកម្មភាព និងសមត្ថភាពសំរាប់ការធ្វើផែនការការត្រួត ពិនិត្យតាមដាន និងវាយតំលៃកម្មវិធី នឹងគំរោងយេនឌ័រ

ង/ គាំទ្រ និងជំរុញការបង្កើនចំណេះដឹងជាសាធារណៈអំពីយេនឌ័រ និងកិច្ចអភិវឌ្ឍន៍

## ៥.២.សកម្មភាព និង ចំនុចសំខាន់ៗក្នុងការបញ្ជ្រាបយេនឌ័រ

- ជំរុញអោយមានគោលនយោបាយ និងផែនការកម្មវិធីដែលឆ្លើយតបទៅនឹងយេនឌ័រ
- ជំរុញ និងធ្វើសកម្មភាពក្នុងការបណ្តុះបណ្តាលយេនឌ័រ
- បង្កើតយន្តការ និងបណ្តាញការងារយេនឌ័រ

## ៥.៣. ការបង្កើតភាពអង់អាចរបស់ ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍន៍

- ក្នុងការគ្រប់គ្រង
- ការចូលរួម
- ចំណេះដឹងជាចាំបាច់ ការកើនឡើងនូវសមភាព និងអំណាច
- សុខុមាលភាព
- ការទទួលបាន ឬការប្រើប្រាស់

## ៥.៤. សកម្មភាពជាអទិភាពសំរាប់គាំទ្រស្ត្រី និងការបញ្ជ្រាបយេនឌ័រតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់

- បណ្តុះបណ្តាលដល់ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់អំពី :
  - " ស្ត្រី និង អភិបាលកិច្ចល្អ "
  - ស្ត្រីនិងមគ្គទ្ទេសក៍ភាព
  - គោលការណ៍អភិបាលកិច្ចល្អ និងគោលការណ៍ចាត់ចែង
- គាំទ្រ និងជំរុញការបង្កើតបណ្តាញ និងវេទិកាស្ត្រី សំរាប់ការងារយេនឌ័រនៅមូលដ្ឋាន
- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធដើម្បីជំរុញអោយរៀបចំគោលនយោបាយសំរាប់ ស្ត្រី
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់នូវការអប់រំខាងសមត្ថភាពជំនាញសំរាប់ស្ត្រី

*ខាងក្រោមនេះជាប្រវត្តិខ្លះៗ ទាក់ទងទៅនឹងស្ត្រី ក្រោមប្រធានបទ :*

**១. ស្ត្រី ក្នុងការអភិវឌ្ឍន៍ (WID)**

**២. យេនឌ័រ និងការអភិវឌ្ឍន៍ (GAD)**

អង្គការសហប្រជាជាតិបានចាប់ដំណើរនៅឆ្នាំ ១៩៤៥ ប៉ុន្តែនារីអន្តរជាតិ ៨ មីនា ដែលជាលទ្ធផលនៃការតស៊ូរើបំរះរបស់ស្ត្រី ដើម្បីទាមទារសិទ្ធសេរីភាពក្នុងការងារ និងការទទួលបាននូវប្រាក់កំរៃអោយបានស្មើភាពជាមួយបុរស បានចាប់ផ្ដើមតាំងពី ថ្ងៃទី ៨ មិនាឆ្នាំ ១៩១១ មកម្លេះ ។

មុនឆ្នាំ

១៩៧០ : គេយល់ថា ការអភិវឌ្ឍន៍ពុំចាំបាច់មានស្ត្រីទេ

១៩៧០ : តួនាទីស្ត្រីក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ត្រូវបានកែសំរួល

១៩៧៣ : នៅវ៉ាស៊ីងតោនសហរដ្ឋអាមេរិក គេបញ្ចូលស្ត្រីទៅក្នុងកិច្ចអភិវឌ្ឍន៍ ដែលហៅកាត់ថា (WID)

១៩៧៥ : សន្និសីទអន្តរជាតិបានកំណត់ឆ្នាំអន្តរជាតិរបស់ស្ត្រី និងទសវត្សរបស់ស្ត្រី នៅទីរកុងម៉ិចស៊ិចកូ ដែលមានប្រធានបទបីគឺ អភិវឌ្ឍន៍ សមភាព និងសន្តិភាព ។

១៩៨០ : សន្និសីទពិភពលោករបស់ស្ត្រីសំរាប់ពាក់កណ្ដាលទសវត្សរបស់ស្ត្រីនៅទីក្រុងជ្យូផនេហាងនេ ប្រទេសដាណឺម៉ាក បានធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ផែនការសកម្មភាពដែលស្ដីពីសមភាព សន្តិភាព និងអភិវឌ្ឍន៍

១៩៨៥ : សន្និសីទស្ត្រីនៅចុងទសវត្សនៅ ណៃរ៉ូបិប្រទេសខេនយ៉ា

១៩៩៥ : សន្និសីទលើកទី ៤ របស់ស្ត្រី នៅក្រុងប៉េកាំងបានលើកឡើងពីកង្វល់របស់ស្ត្រី១២ចំនុចនៅទូទាំងពិភពលោកគឺ: ភាពក្រីក្រ ការអប់រំ សុខភាព បរិស្ថាន វិសមភាពយេនឌ័រ និងភាពរើសអើង ប្រឆាំងនឹងស្ត្រី សិទ្ធិស្ត្រី ការផ្សព្វផ្សាយអំពើហឹង្សាប្រឆាំងនឹងស្ត្រី ផលវិបាកនៃជំលោះអាវុធ រចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយ វិសមភាពក្នុងការធ្វើសេចក្ដីសំរេច និងបញ្ហាកុមារី ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះគេបានគិតគូរឡើងវិញពីយេនឌ័រនិងការអភិវឌ្ឍន៍ ដែលហៅកាត់ថា GAD សមស្របទៅនឹងការរីកចំរើនផ្នែកសមត្ថភាពរបស់បុរស និង ស្ត្រីជាការពិនិត្យឡើងវិញពីទំនាក់ទំនងដែលមិនអាចខ្វះបានរវាងបុរស និងស្ត្រី ដែលចាំបាច់ត្រូវតែពឹងពាក់អាស្រ័យគ្នា និងបំពេញការខ្វះខាតគ្នាទៅវិញទៅមក ព្រោះភេទទាំងពីរមានទស្សនៈបទពិសោធន៍សេចក្ដីត្រូវការ និងផលប្រយោជន៍ដោយឡែកពីគ្នា ។

***ហេតុដូចម្តេច ចាំបាច់ត្រូវមានស្ត្រីចូលរួមក្នុងការអភិវឌ្ឍន៍ ?***

ព្រោះ :

១. ទិសដៅនៃការអភិវឌ្ឍន៍ គឺលើកស្ទួយជីវភាព កាត់បន្ថយ និងលុបបំបាត់ភាពក្រីក្រ ។ ស្ត្រីគឺជាក្រុមដែលក្រីក្រជាងគេ មានចំនួនច្រើនជាងគេ និងរងនូវសំពាធសង្គមច្រើនជាងគេ ដូច្នេះត្រូវតែចាប់ផ្តើមពីស្ត្រី ។

២. ការងាររបស់ ស្ត្រីពុំទាន់បានទទួលនូវប្រាក់កំរៃ និងតំលៃសមរម្យនៅឡើយ ។

៣. រចនាសម្ព័ន្ធផ្នែកសេដ្ឋកិច្ច នយោបាយ ដាក់ស្ត្រីអោយស្ថិតនៅក្នុងស្រទាប់ក្រោម ដែលពុំមានតួនាទីជាអ្នកអាចសំរេចបាន ។

៤. មតិយោបល់របស់ស្ត្រីមិនត្រូវបានគេរាប់បញ្ចូលជាអាទិភាព និងអាចគេបំភ្លេចចោល ។

៥. ទស្សនៈសង្គមនៅតែបន្តអោយតំលៃទាបចំពោះស្ត្រីនៅឡើយ ។

៦. ស្ត្រីគឺជាដៃម្ខាងក្នុងចំណោមដៃទាំងពីរក្នុងការអភិវឌ្ឍន៍ បើស្ត្រីមិនបានចូលរួមបានសេចក្តីថា គេពុំទាន់បានប្រើប្រាស់ធនធានមនុស្សដែលមានទាំងអស់ឡើយ ។

**ផលប្រយោជន៍យេនឌ័រ**

**កែប្រែសង្គមដោយសន្តិវិធី** | **ជំរុញការអភិវឌ្ឍន៍ដោយស្មើភាព**

- សង្គមកសាងទស្សនៈបែងចែកចំពោះភេទ តែសង្គមអាចកែប្រែបានដោយសារមនុស្ស
- យេនឌ័រ គឺជាមូលដ្ឋានគ្រឹះ និងជាហេតុផលនៃសិទ្ធិមនុស្ស
- គាំទ្រស្ត្រី គឺគាំទ្រការអភិវឌ្ឍន៍ជាតិ

# ប្រសិទ្ធិភាពនៃការធ្វើការងារជាក្រុម

របៀបដឹកនាំឃុំ-សង្កាត់ នៅក្នុងប្រព័ន្ធវិមជ្ឈការមានលក្ខណៈខុសគ្នាដាច់ស្រលះពីរបៀបរបប ដឹកនាំ ឃុំ-សង្កាត់ កាលពីលើកមុន ។ ពោលគឺលើកមុនឃុំ-សង្កាត់ ដឹកនាំដោយមេឃុំ ចៅសង្កាត់តែម្នាក់ឯង រួមជាមួយនិងមន្ត្រីឃុំ-សង្កាត់មួយចំនួនទៀត ដែលកើតឡើងពីការតែងតាំង ។ ប៉ុន្តែបច្ចុប្បន្ននេះឃុំ-សង្កាត់ ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាមួយឈ្មោះថា "ក្រុមប្រឹក្សា ឃុំ-សង្កាត់ " ដែលក្រុមប្រឹក្សានេះត្រូវបាន ជ្រើសតាំងឡើងដោយការបោះឆ្នោតពីសំណាក់ប្រជាពលរដ្ឋ ។

មានសុភាសិតមួយនិយាយថា "សាមគ្គី គឺជាកត្តានាំមកនូវជ័យជំនះ " ។ ដូចនេះសួរថា តើការប្រកាន់បក្ខពួកនិន្នាការនយោបាយ ឬគណបក្ស ឬការបែកបាក់ផ្ទៃក្នុង តើជាប្រភពនាំអោយការបំពេញ ការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានទទួលជោគជ័យឬទេ ? ។ ការដែលក្រុមប្រឹក្សាឃុំ-សង្កាត់ អាចជ្រើសរើសវិធីមួយដែលធ្វើការងារជាក្រុមដោយគ្មានភាពសៅហ្មងជាមួយគ្នា គឺជំហានដ៏មានប្រសិទ្ធមួយ ដែលអាចជំរុញអោយដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ឈានទៅដល់គោលដៅជោគជ័យ ស្របតាម ទិសដៅដែលបានគ្រោងទុក ។

## ១. ប្រសិទ្ធិភាពនៃការធ្វើការងារជាក្រុម :

**និយមន័យ**

ការធ្វើការងារជាក្រុមសំដៅលើការប្រតិបត្តិការងាររួមគ្នារបស់សមាជិកក្រុម ដើម្បីអោយបានសំរេច គោលដៅដែលក្រុមត្រូវការ ។

**លក្ខខ័ណ្ឌការងារជាក្រុមរួមមាន :**

១. មានគោលដៅរួម

២. មានចំណែករួមក្នុងការធ្វើការងារ

៣. មានទំនាក់ទំនងរវាងគ្នា នឹងគ្នា

៤. មានកិច្ចសហប្រតិបត្តិការរួមគ្នា

៥. មានការសំរេចចិត្តរួមគ្នា

៦. មានផលប្រយោជន៍រួមគ្នា ។

## សារៈសំខាន់នៃការធ្វើជាក្រុម

១. មនុស្សមានដែនកំនត់ក្នុងរឿង "ថាមពល" ដូច្នេះការធ្វើការតែឯកឯង រមែងតែងតែបានទទួលលទ្ធិផលដ៏ពិបាកដោយចំពោះការងារធន់ៗ ត្រូវពឹងអាស្រ័យអ្នកដ៏ទៃចូលរួម ។

២. មនុស្សជាភាពបន្ទាប់បន្សំមួយនៅក្នុងសង្គមមិនអាចរស់នៅតែឯងបានឡើយ រមែងអាស្រ័យការពឹង ពាក់គ្នាទៅវិញទៅមក ។

៣. មនុស្សយើងមានការខុសប្លែកគ្នាខាងសតិបញ្ញាចំណេះ និងសមត្ថភាពប្រសិនបើបានរួមគំនិតរួមគ្នាធ្វើ និងជំរុញអោយមានភាពប្រាកដប្រជាជុំវិញខ្លួនថែមទៀងផង ។

៤. លក្ខណៈសង្គមបច្ចុប្បន្ននេះ ចាំបាច់ត្រូវសហការគ្នាធ្វើការងារគ្រប់លំបាកជាន់ថ្នាក់ ដើម្បីដោះស្រាយបញ្ហាអោយមានប្រសិទ្ធភាពកាន់ខ្លាំងឡើង ។

៥. ការធ្វើការងារជាក្រុមរមែងតែងតែទទួលបាន លទ្ធផលប្រសើរជាងការធ្វើការតែឯង ។

៦. បុគ្គលដែលមានឱកាសចូលរួមធ្វើការជាក្រុម រមែងមានឱកាសរៀនសូត្រពីគ្នា ហើយក៏មានការអភិវឌ្ឍន៏ផងដែរព្រមទាំងនាំអោយមានភាពរីកចំរើនលូតលាស់នោះឆ្ពោះទៅក្រុមការងារផងដែរ ។

**កត្តានៃការធ្វើការងារជាក្រុម :**

១. អ្នកដឹកនាំក្រុមដ៏ល្អម្នាក់ត្រូវមាន :

- ចំណេះ និងសមត្ថភាពគ្រប់គ្រាន់។
- ដឹងមុខនាទី និងការងាររបស់ខ្លួន។
- អាចទាក់ទាញទឹកចិត្តមនុស្សបាន។
- ព្យាយាមធ្វើយ៉ាងណាអោយខ្លួនទាន់សម័យ។
- មានចិត្តទូលាយបើកចំហ។
- ជាគំរូដ៏ល្អ។
- មានវិសាលភាព។
- ស្គាល់កាលៈទេសៈ។

២. សមាជិកដ៏ល្អនៅក្នុងក្រុមត្រូវមាន :

- ស្គាល់មុខនាទីរបស់ខ្លួន។
- គោរពពេលវេលា។

- រក្សារបៀបរៀបរយ ។
- រួមសហការផ្តល់គំនិត ។
- គោរពសិទ្ធិ ផ្តល់កិត្តិយសឱ្យគ្នា ។

៣. វិធី របៀប› ធ្វើការងារជាក្រុមត្រូវមាន :

- ដាក់ផែនការល្អ ។
- ជម្រះរាល់បញ្ហាទាស់ទែងគ្នា ។
- មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ផ្ទាល់បុគ្គល› ។
- មានការប្រតិបត្តិ ។

## កិច្ចការជាក្រុម



## ២.ការមិនប្រកាន់និន្នាការនយោបាយ :

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ មាត្រា ៩ ចែងថា : ឃុំ/ សង្កាត់ និមួយៗត្រូវមានក្រុមប្រឹក្សាមួយ ហៅថាក្រុមប្រឹក្សា ឃុំ/សង្កាត់ ) ។ ក្រុមប្រឹក្សា ឃុំ/សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់ របស់ខ្លួន និង មានបេសកម្មបំរើផលប្រយោជន៍ទូទៅក្នុង ឃុំ /សង្កាត់ របស់ខ្លួន ។

មាត្រានេះបង្ហាញយ៉ាងច្បាស់លាស់ ដើម្បីកំណត់ពីអត្តសណ្ឋាណរបស់ឃុំ/សង្កាត់ ។ ដូចនេះមានន័យថាក្រុមប្រឹក្សាឃុំ

- សង្កាត់នឹងពុំមានការភាន់ច្រលំអំពីអត្តសញ្ញាណរបស់ខ្លួនទេ ។ អ្វីដែលក្រុមប្រឹក្សាឃុំ /សង្កាត់គួរចងចាំ ដើម្បីអោយដំណើការប្រព្រឹត្តទៅរបស់ខ្លួនស្របច្បាប់ និងលិខិតបទដ្ឋានផ្សេងៗនោះ គឺ :

- ក្រុមប្រឹក្សា ឃុំ /សង្កាត់ កើតឡើងពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋក្នុងឃុំ /សង្កាត់ របស់ខ្លួនជាអង្គការ តំណាងអោយប្រជាពលរដ្ឋក្នុងឃុំ ,សង្កាត់របស់ខ្លួន និងមានបេសកម្មបំរើផលប្រយោជន៍ ទូទៅក្នុងឃុំ /សង្កាត់ របស់ខ្លួន ។

✧ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា១០ ចែងថា " ក្រុមប្រឹក្សា ឃុំ/សង្កាត់ នីមួយៗត្រូវ ជ្រើសរើសឡើងដោយការបោះឆ្នោតដោយប្រជាពលរដ្ឋនៃឃុំ/សង្កាត់ របស់ខ្លួន " ។

តាមរយៈមាត្រានេះ បានបង្ហាញថា អំណាច និងតួនាទីរបស់ក្រុមប្រឹក្សា ឃុំ/សង្កាត់ បានមកដោយសារការបោះឆ្នោតពីប្រជាពលរដ្ឋក្នុងឃុំ /សង្កាត់ នោះមិនមែនដោយសារគណបក្សនយោបាយប្រគល់អោយនោះទេ ។ ការមិនប្រកាន់និន្នាការនយោបាយ គឺជាប្រសិទ្ធិភាពដំបូងដែលអាចនាំអោយក្រុមប្រឹក្សា ឃុំ / សង្កាត់ ធ្វើការប្រកបដោយលទ្ធផលល្អទាំងការគ្រប់គ្រង ក៏ដូចជាការអភិវឌ្ឍន៍ ឃុំ /សង្កាត់ ។ តាមរយៈបទពិសោធន៍ នៃការ ធ្វើការងារជាក្រុម ដែលមានសមាសភាពនយោបាយពីប្រភពផ្សេងគ្នា បានបង្ហាញអោយឃើញថា : ទោះបីជាក្រុម ណាមួយសំបូរដោយបុគ្គលមានបទពិសោធន៍យ៉ាងណាក្តី ក៏ការដឹកនាំនិងការបំពេញការងារពុំសូវមានប្រសិទ្ធិភាព និងជោគជ័យឡើយប្រសិនបើក្រុមណាមួយនោះ **ប្រកាន់និន្នាការនយោបាយរៀងខ្លួន ។**

រូបមន្តដ៏មានសារសំខាន់ដែលអាចរួមចំនែកអោយការគ្រប់គ្រង និងការអភិវឌ្ឍន៍ ឃុំ /សង្កាត ទទួលបាន ជោគជ័យ :

- គោរពច្បាប់និងលិខិតបទដ្ឋាននានា
- ចេះធ្វើការងារជាក្រុម
- ចែករំលែកការទទួលខុសត្រូវ និងមានកិច្ចសហប្រតិបត្តិការគ្នាល្អ

- ធ្វើខ្លួនអោយក្លាយជាអ្នកតំណាងប្រជាពលរដ្ឋពិតប្រាកដ
- យកផលប្រយោជន៍ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ /សង្កាត់ ជាធំ
- មានគំនិតបើកទូលាយអោយមានការចូលរួមពីក្រុមពាក់ព័ន្ធ

✧ ច្បាប់ស្តីពីការគ្រប់គ្រង ឃុំ សង្កាត់ មាត្រា ៤១ ចែងថា " រដ្ឋបាលឃុំ /សង្កាត់មានតួនាទី ជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាសធនធាននានា សំរាប់បំពេញសេចក្តីត្រូវការ ជាមូលដ្ឋាន ក្នុង ឃុំ /សង្កាត់ របស់ខ្លួនបំរើផលប្រយោជន៍ ប្រជាពលរដ្ឋ និង គោរពផលប្រយោជន៍ជាតិស្របតាម គោលការ ទូទៅរបស់រដ្ឋ " ។

## ៣. ការគោរពតួនាទី ភារកិច្ច និងកិច្ចសហការគ្នា :

ការគោរពតួនាទី និងភារកិច្ច ក៏ដូចជាការគោរពនូវការបែងចែកការទទួលខុសត្រូវចំពោះមុខនាទី និងភារកិច្ច របស់ខ្លួនក៏ជាមធ្យោបាយមួយធ្វើអោយក្រុមប្រឹក្សាឃុំ សង្កាត់ អាចបំពេញការងារមួយដែលមាន ប្រសិទ្ធិភាព និងគុណភាពផងដែរ ។ ប៉ុន្តែការទទួលខុសត្រូវចំពោះមុខនាទីនេះ មិនមានន័យថាក្រុមប្រឹក្សា ម្នាក់ៗ ដែលទទួលការងារនោះក្នុង គ្របខណ្ឌ័ជាកម្មសិទ្ធិផ្តាច់មុខតែឯងមិនអោយនណាចូលរួម ឬក៏ចង់សំរេច យ៉ាងណាបានស្រេចតែចិត្តនោះទេ។ រី ឯ អ្នកស្ថិតនៅក្រៅការទទួលខុសត្រវក៏ដូចគ្នា ពុំមានន័យថាយើងធ្វើ មិនដឹងធ្វើមិនលឺពីការងារ ឬការទទួលខុសត្រូវ របស់អ្នកដ៏ទៃនោះទេ ។ គោលបំណង នៃការបែងចែកមុខ នាទី ភារកិច្ច និងការទទួលខុសត្រូវ គឺដើម្បីកុំអោយបុគ្គលម្នាក់ៗ ធ្វើការជាន់គ្នាលើការងារមួយ ហើយទុក ការងារមួយទៀតនៅទំនេរ ពិសេស ដើម្បីជៀសវាងការ ដណ្តើមការងារធ្វើតែម្នាក់ឯងដោយពុំមានការចូល រួមទទួលខុសត្រូវពីអ្នកពាក់ពន្ធ័ដ៏ទៃ ទៀត ។

**ប៉ុន្តែទោះបីជាមានការបែងចែកមុខនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលណាមួយទៅ លើ ការងារអ្វីក៏ដោយ ក៏គប្បីចាំថាអ្នកទទួលខុសត្រូវលើការងារដែលបានប្រគល់នោះ គឺទទួលខុសត្រូវក្នុង នាម ក្រុមប្រឹក្សា ឃុំ ,សង្កាត់ និងដើម្បីបំរើផលប្រយោជន៍ ឃុំ/សង្កាត់ ។**

ក្រុមប្រឹក្សាឃុំ សង្កាត់ គប្បីចងចាំមាត្រាខ្លះនៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ ដែលមានការ ពាក់ពន្ធ័ទៅនឹងការបំពេញភារកិច្ចរបស់ខ្លួនដូចតទៅនេះ :

✧ មាត្រា ៥៤ :ចំនុចទី១ចែងថា " ឃុំ ,សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ ដើម្បីអោយមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវអោយ នោះ ជាបន្ទាន់ " ។

✧ មាត្រា ៥៧ ចែងថា កាលបើ ការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បាន តំរូវណាមួយ ឬ មួយចំនួនអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់ បានតម្រូវជាទូទៅ ក្រុម ប្រឹក្សា ឃុំ .សង្កាត់ ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សា ឃុំ/សង្កាត់ ហើយ ធ្វើការបោះឆ្នោតឡើងវិញ " ។

តាមរយៈមាត្រាទាំងពីរខាងលើនេះ បញ្ជាក់ថា ការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សា ឃុំ /សង្កាត់ គឺជាការទទួលខុសត្រូវរួម គ្នារបស់ក្រុមប្រឹក្សា ឃុំ /សង្កាត់ ទាំងមូលចំពោះមុខច្បាប់ ។

ដូចនេះមានន័យថា កិច្ចសហប្រតិបត្តការគឺ ជាប្រភពនៃជ័យជំនិះរបស់ក្រុមប្រឹក្សា ឃុំ /សង្កាត់ក្នុង ការគ្រប់គ្រង និងអភិវឌ្ឍន៏មូលដ្ឋានឃុំ សង្កាត់របស់ខ្លួន ។

# ការអភិវឌ្ឍន៍ដែលមានការចូលរួមពីប្រជាពលរដ្ឋ

គោលបំណងនិងទិសដៅនៃវិមជ្ឈការ គឺផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៏មូលដ្ឋាន ក៏ដូចជាការកែប្រែជីវភាពរបស់គាត់ដោយផ្ទាល់ ។ ដូចនេះមានន័យថា ប្រសិនបើ គ្មានការចូលរួមពី ប្រជាពលរដ្ឋទេ នោះមានន័យថាប្រទេសយើងពុំមានការអភិវឌ្ឍន៏នយោបាយវិមជ្ឈការទេ ។

កំរិតនៃការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ពុំអាចឆ្លុះបញ្ចាំងផងដែរពីកំរិត នៃភាពជោគជ័យនៃការ អភិវឌ្ឍន៏នយោបាយវិមជ្ឈការ ។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៏វិមជ្ឈការ គឺបានបញ្ជាក់ថា ប្រជាពលរដ្ឋបានចូលរួមដោយផ្ទាល់ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ខ្លួនឯង ។

**○ ទិសដៅវិមជ្ឈការនិងការគ្រប់គ្រងឃុំ/សង្កាត់មានបីចំនុចធំៗ គឺ:**

ក. ផ្តល់ឱកាសឱ្យប្រជាជននៅតាមមូលដ្ឋាន មានឱកាសកាន់តែទូលំទូលាយនៅក្នុងការសំរេចចិត្ត ដែលមាន ផលប៉ះពាល់លើជីវភាពរស់នៅរបស់ពួកគាត់ និងនៅក្នុងការកំណត់អនាគតរបស់ពួកគាត់ ។

ខ. លើកកំពស់លទ្ធិប្រជាធិតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ ។

គ. ធានាការអភិវឌ្ឍន៏ប្រកបដោយចីរភាព រួមមានការផ្តល់សេវាជាមូលដ្ឋានផងដែរ ។

ក្នុងមាត្រានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ ,សង្កាត់ មាត្រា ២៧ចែងថា " មេឃុំ ចៅសង្កាត់ មានសិទ្ធិ ចាត់តាំងគណៈកម្មាធិការនានា ដើម្បីផ្តល់យោបល និងជួយកិច្ចការនានាតាមការចាំបាច់ " ។ គណៈកម្មាធិការខាងលើនេះ អាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ ,សង្កាត់ ឱ្យធ្វើជាប្រធានក៏បាន ឬអាចយក ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតម្នាក់ក្នុងឃុំ /សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ ជាប្រធាន ក៏បាន ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា៦៤ ចំនុចទី២ចែងថា " ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិង មធ្យោបាយនានា ដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ក្នុង ឃុំ /សង្កាត់របស់ខ្លួន ក្នុងកិច្ចដំណើរការទាំងមូល " ។

បើពិនិត្យទៅលើខ្លឹមសារទាំងពីរ នៃមាត្រាខាងលើនេះ សុទ្ធតែបង្ហាញអោយឃើញនូវការបង្កលក្ខណៈអោយមានការចូលរួមពីប្រជាពលរដ្ឋទាំងក្នុងសកម្មភាពដឹកនាំ ទាំងក្នុងសកម្មភាពកសាងផែនការអភិវឌ្ឍន៍ ឃុំ ,សង្កាត់ ។

## ១. ផលប្រយោជន៍នៃការចូលរួម

### ☛ តើផលប្រយោជន៍នៃការចូលរួមមានអ្វីខ្លះ ?

- ប្រជាពលរដ្ឋមានអារម្មណ៍ទទួលខុសត្រូវកាន់តែច្រើនឡើង ចំពោះគំរោងនានាក្នុងមូលដ្ឋានរបស់ខ្លួន នៅពេលដែលពួកគេមានការពាក់ពន្ធ័ នៅក្នុងការសំរេចចិត្តអនុវត្ត និងពិនិត្យតាមដាន និងវាយតំលៃ សកម្មភាពអភិវឌ្ឍន៍ទាំងឡាយ ។
- ការចូលរួមធានាអោយបានថា គំរោងនានាពិតជាបានឆ្លើយតបនឹងផលប្រយោជន៍ និងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលជាហេតុធ្វើឱ្យគំរោងនេះទទួលជោគជ័យកាន់តែច្រើនឡើងថែមទៀត ។
- ការចូលរួមកាន់តែធ្វើឱ្យប្រជាពលរដ្ឋកាន់តែឯករាជ្យពីជំនួយខាងក្រៅ ដោយសារប្រជា-ពលរដ្ឋចាប់ ផ្តើមគិតគូ ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ខ្លួនហើយផ្តួចផ្តើមចាត់វិធានការ ។

- ការចូលរួមគាំទ្រកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រ ពីព្រោះជនក្រីក្របានចូលរួមផងដែរ ។
- ការចូលរួមនឹងជួយក្រុមប្រឹក្សាឃុំ /សង្កាត់ផងដែរ ក្នុងការប្រើប្រាស់ធនធានរបស់ខ្លួនឱ្យកាន់តែមានប្រ សិទ្ធិភាព ។

## ២. ការជំរុញការចូលរួមរបស់សាធារណៈជន

### តើការជំរុញការចូលរួមរបស់សាធារណៈជន អាចធ្វើឡើងតាមវិធីណាខ្លះ ?

- នៅក្នុងអង្គប្រជុំក្នុងភូមិ ប្រជាពលរដ្ឋមានឱ្យកាសពិភាក្សាអំពីតំរូវការ និងផលប្រយោជន៍របស់ខ្លួន ។ ក្រុមប្រឹក្សា ត្រូវធានាឱ្យបានថា ប្រជាពលរដ្ឋនៅគ្រប់ផ្នែកទាំងអស់ក៏ដូចជាស្ត្រី បុរស អ្នកមាន អ្នកក្រ បាន ចូលរួមក្នុងកិច្ចពិភាក្សានេះ ។
- អង្គការសង្គមស៊ីវិល អាចរួមចំនែក ចំពោះការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគដោយ ធ្វើជាតំណាងអោយផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងក្រុមប្រជាពលរដ្ឋជាក់លាក់ ដូចជាជនក្រីក្រ ស្ត្រី និងជនជាតិភាគតិច ។
- អង្គការសង្គមស៊ីវិល អាចផ្តល់ចំណេះដឹង និងមតិរបស់ខ្លួនសំរាប់រៀបចំផែនការអភិវឌ្ឍន៍ ។
- សាធារណៈជនមានឱកាសផ្តល់មតិ យោបល់ចំពោះផែនការអភិវឌ្ឍន៍ ។
- ប្រជាពលរដ្ឋត្រូវចូលរួមនៅក្នុងការត្រួតពិនិត្យការអនុវឌ្ឍន៍ផែនការអភិវឌ្ឍន៍ ។
- ការចុះទៅធ្វើការប្រាស្រ័យទាក់
- ការចុះទៅធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ។

### សំនួរពិភាក្សា

១. ដើម្បីអោយមានសមភាពផ្នែកយេនឌ័រក្នុងសង្គមជាតិ តើយើងគួរធ្វើដូចម្តេច ?

២. ដើម្បីកាត់បន្ថយអំពើហិង្សា តើយើងគួរធ្វើដូចម្តេច ?

៣. ចូរនិយាយពីតួនាទី បុរស និងស្ត្រីក្នុងគ្រួសារ

# ឯកសារយោង

១. វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ -សង្កាត់ របស់គណៈកម្មាធិការជាតិ គាំទ្រ ឃុំ .សង្កាត់

២. អភិបាលកិច្ចល្អរបស់នាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

៣. ឯកសារបណ្តុះបណ្តាលរបស់អង្គការចំរើនស្ត្រី

៤. តើអ្វីខ្លះដែលលោកអ្នកចង់ដឹងអំពីវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ /សង្កាត់ នៅកម្ពុជា របស់គណៈកម្មាធិការជាតិ គាំទ្រ ឃុំ /សង្កាត់

៥. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់